សារព័ត៌មាន ខ្មែរផុស ស.រ.អា.
KhmerPost USA
FREE BIWEEKLY CAMBODIAN ENGLISH NEWSPAPER SINCE 2007
978-677-7163 • VISIT KHMERPOST.US

7 Video
ទទួលផ្ញើអីវ៉ាន់ ទៅវិញទៅមកស្រុកខ្មែរ
- ផ្ញើ១ផោន តម្លៃ ១០ដុល្លារ
- ធនា បើសិន បាត់ ឬបាក់បែក
- ដឹកជញ្ជូនដល់ផ្ទះ
ទំនាក់ទំនង ៖ Mr. យុទ្ធ (978) 876-1985
660 Middlesex St., Lowell, MA 01851
(978)710-6356

Cambodia dailly

## បោះឆ្នោតនៅកម្ពុជាឯកអគ្គរដ្ឋទូតអាមេរិកនិយាយ

"រដ្ឋាភិបាលអាមេរិកមានការកោតសរសើរដល់ការបោះឆ្នោតនៅកម្ពុជាតែខកចិត្តនឹងបរិយាកាសគម្រាមកំហែងពេលមុនការបោះឆ្នោត" ដូចជារដ្ឋមន្ត្រីក្រសួងការពារជាតិនិយាយពីការ "វាយបាក់ធ្មេញ" លោកនាយករដ្ឋមន្ត្រីនិយាយពីការប៉ុនប៉ង"សម្លាប់មនុស្ស១០០-២០០នាក់បើបក្សប្រឆាំងឈ្នះ" ...

## GOVERNMENT PANS US AMBASSADOR'S CALL FOR LESS SUSPICION, THREATS

**by Ben Paviour | June 9, 2017**

U.S. Ambassador William Heidt yesterday praised the commune elections but denounced pre-election threats, saying the Cambodian govern-



US Ambassador William Heidt leaves the CNRP's headquarters in Phnom Penh in2016 after a meeting with deputy opposition leader KemSokha. (Siv Channa/The Cambodia Daily)

ment was too suspicious of U.S. intentions, **Continued to Page 05**

# បោះឆ្នោតឃុំសង្កាត់: នៅតិចជាង៥%ទៀតសង្គ្រោះជាតិនឹងឈ្នះ

**ដោយ ពិន សំខុន**

ក្នុងបណ្តាខេត្រ២៥នៅកម្ពុជា មានឃុំសង្កាត់ចំនួន១៦៤៦ ដែលការបោះឆ្នោតកាលពីថ្ងៃ៤ ខែមិថុនាឆ្នាំ២០១៧ បានលទ្ធផលបណ្តោះអាសន្នចែកឃុំសង្កាត់នយោបាយទៅជា ឃុំដែលមានមេឃុំមកពីគណបក្សប្រជាជនមាន១១៥៩ នឹងមានឃុំសង្កាត់មកពីគណបក្សសង្គ្រោះជាតិមានចំនួនជិត៤៨៦ឬបើគិតពីចំនួនអ្នកបោះឆ្នោតវិញ គណបក្សប្រជាជនបាន៤៨% គណបក្សសង្គ្រោះជាតិបាន៤៥% (លទ្ធផលថ្លែងដោយនីហ្វេកអង្គការឃ្លាំមើលឯករាជ្យ) គំលាតគ្នាមានតែតិចជាង៥%តែប៉ុណ្ណោះ។ **តទៅទំព័រទី ០៦**



# គ្រោះថ្នាក់នៅសមុទ្រលោក ឈៀង ឈុន លង់ទឹកស្លាប់



សុខផល ប៉ែន



លោក ឈៀង ឈុន

**ដោយខ្មែរផុស ស.រ.អា. ឡូវែលៈ** ថ្ងៃអង្គារទី៦ ខែមិថុនា ឆ្នាំ២០១៧ វេលាម៉ោង៤រសៀល លោក ឈៀង ឈុន នឹងលោក សុខផល ប៉ែន ប្រធានយុវជនគណបក្សសង្គ្រោះជាតិសហរដ្ឋអាមេរិក មានទីលំនៅនៅឡូវែលបានចេញទៅកំសាន្តតាមកាណូតសមុទ្រដើម្បីទៅស្ទូចត្រីនៅមាត់សមុទ្រសាលីបូរី។

គាប់ជួនខ្យល់ព្យុះកើតរលក៨មកដល់រលកធំៗបោកបក់ខ្លាំងនាកណ្តាលសមុទ្របានធ្វើឱ្យកាណូតរបស់អ្នកទាំងពីរក្រឡាប់ផ្ងារពោះឡើងលើធ្វើ **តទៅទំព័រទី ០៥**

មេធាវី លុយហាស្កែល
Law Office of Louis S. Haskell
Serving the Cambodian Community since 1987
PERSONAL INJURY របួសរាងកាយ
AUTO ACCIDENTS គ្រោះថ្នាក់ចរាចរ





978-459-8359
16 Pine Street - Lowell, MA | www.attorneyhaskell.com

KhmerPost USA
Cambodian American Biweekly Newspaper
Connecting 10,000 Khmer-speaking households per Month with an average of 5 members per household. Free Newspaper copies are available in these cities:
Massachusetts:
- Lowell
- Lynn/Revere

Rhode Island:
- Providence
- Cranston

CELEBRATING 10 YEARS
Contact us for the Advertising Opportunity!
978-677-7163 | http:/khmerpost.us

# “ខលី” ឬ “ដោនថោន” ដាន់ រូក បញ្ចេញមតិ

## Cawley or Downtown : Dan Rourke Speaks Out

**ដោយ ពិន សំខុន**

*សមាជិកក្រុមប្រឹក្សាឡូវែលនឹងធ្វើការសម្រេចចិត្តចំពោះទីតាំងរបស់វិទ្យាល័យរបស់ខ្លួននៅថ្ងៃអង្គារទី១៣មិថុនា, ដែលជាសេចក្ដីសម្រេចចិត្តដ៏មានការទទួលខុសត្រូវធំបំផុតមួយ ពីព្រោះវានឹងប៉ះពាល់ដល់វាសនាអនាគតនៃមធ្យមសិក្សានៅក្រុងឡូវែលនេះ រួមទាំងវាសនាអនាគតនៃមណ្ឌលពាណិជ្ជកម្មនៅ"ដោនថោន"ផងដែរ។ លោក ដាន់ រូក ជា"ចៅហ្វាយក្រុងរង"នៅក្រុងឡូវែល លោកបានផ្ដល់បទសម្ភាសន៍ដល់ខ្មែរផុស កាលពីថ្ងៃព្រហស្បតិ៍ទី៨កន្លងទៅនេះ នៅភោជនីយដ្ឋាន"អាថេនីញ៉ាន"និយាយពីទស្សនៈរបស់លោកផ្ទាល់ស្ដីពីការធ្វើសេចក្ដីសម្រេចចិត្តលើរឿងដ៏មានសារៈសំខាន់នេះ ដែលនឹងប៉ះពាល់ដល់ស្ថានភាពសិក្សានៃប្រជាពលរដ្ឋក្នុងក្រុងរបស់លោកនឹងដល់ជីវិតនយោបាយរបស់លោកផ្ទាល់:*

**ខ្មែរផុសស.រ.អាះ** នៅថ្ងៃអង្គារទី១៣នេះក្រុមប្រឹក្សាក្រុងឡូវែលនឹងធ្វើសេចក្ដីសម្រេចចិត្តដ៏សំខាន់មួយស្ដីពីទីតាំងរបស់"ឡូហាយស្គូល" លោកដែលជាអ្នកបោះឆ្នោតម្នាក់ដែរ តើលោកដឹងទេថា លទ្ធផលនឹងក្លាយទៅជាយ៉ាងណា?

**ដាន់ រូកៈ** មែន! យើងនឹងធ្វើការបោះឆ្នោតនៅថ្ងៃទី១៣ តែខ្ញុំច្បាស់ជាមិនដឹងទេថា សាលា "ឡូហាយស្គូល"នឹងនៅទីណានោះទេ គឺជាការបោះឆ្នោតទៅតាមទស្សនៈរបស់សមាជិកក្រុមប្រឹក្សាម្នាក់ៗ...

**ខ្មែរផុសស.រ.អាះ** តើលោកយល់ថា ប្រធានបទនេះបានបែងចែកសាលក្រុងជាខ្លាំងឬ?

**ដាន់ រូកៈ** មែនហើយ ប្រធានបទនេះ បានចែកក្រុងទាំងមូលនឹងចែកក្រុមប្រឹក្សាក្រុងផងដែរ! ហើយម្នាក់ៗសុទ្ធតែមានការយល់ឃើញយ៉ាងវិជ្ជមានទោះជាខាង"ដោនថោន"ក្ដី ឬក៏ខាង "ខលី"ក្ដី ហើយថ្នាក់ដឹកនាំម្នាក់ៗសុទ្ធតែថ្លឹងថ្លែងពីផលប្រយោជន៍របស់អ្នកបង់ពន្ធនឹងពីផលប្រយោជន៍ការសិក្សាយុវជន ចំណែកខ្ញុំយល់ថា ការសម្រេចយក "ខលី"ជាការប្រសើរជាង...

**ខ្មែរផុសស.រ.អាះ** មនុស្សជាច្រើនយល់ថា "ទីតាំងសាលាឡូហាយស្គូល"ដែលនៅកណ្ដាលក្រុងនោះ មិនមានប៉ះពាល់អ្វីដល់ការសិក្សាររបស់សិស្សទេ តែសម្រាប់ខ្ញុំមើលឃើញថា ទុកឱ្យយុវជនដើរពីផ្ទះទៅសាលារៀន ហើយដើរកាត់ទីក្រុងទៀត គឺជាការប្រថុយប្រថាននឹងគ្រោះថ្នាក់សម្បើមណាស់ តែលោកបានយល់ថា "ឡូហាយស្គូល"គួរតែនៅ"ខលី" តើមានហេតុផលអ្វីទេ?

**ដាន់ រូកៈ** ទៅ "ខលី" មានផលចំណេញច្រើន ពីព្រោះជាទ្រង់ទ្រាយជា"ខែមពិស"អ្វីៗក៏មានទាំងអស់នៅក្នុងនោះ ខ្ញុំយល់ពីអារម្មណ៍អ្នក, កូនសិស្សទៅរៀននៅទីនោះ តាំងពីម៉ោង៧ព្រឹក ល្ងាចឡើងម៉ោង៥-៦សឹមមកផ្ទះ ពីព្រោះមាន



លោក ដាន់ រូក

កន្លែងហាត់ប្រាណកន្លែងធ្វើ"ហូមវើក" គឺការងារដាក់ឱ្យធ្វើពីថ្នាក់រៀនមានសកម្មភាពបន្ទាប់ពីថ្នាក់រៀនគ្រប់យ៉ាង, ដែលខ្ញុំយល់ថា នេះជាផលចំណេញដ៏មានសារសំខាន់សម្រាប់សិស្សមិនថាខ្មែរឬសាសន៍ណានោះឡេតែបើក្មេងៗចេញមកធ្វើការងារថ្នាក់បន្ទាប់ពីម៉ោងរៀននៅកណ្ដាលក្រុងមិនជាការប្រសើរប៉ុន្មានទេ, ហើយម្យ៉ាងទៀត ក្រុមពាណិជ្ជករដែលមករកស៊ីនៅ"ដោនថោន"មានប្រាក់ចំណូលប៉ុន្មានពីសិស្សនឹងគ្រូបង្រៀន ? មិនបាន១០%ទេ ខ្ញុំនិយាយនេះមិនជំនួសពាណិជ្ជករទេ តែស្វែងរកផលប្រយោជន៍របស់សិស្ស... នៅមានកង្វះមួយដែរដែលមានអ្នកនិយាយថា ចរាចរនឹងកើនឡើងនៅខលី"ដូច្នេះបើមិនកកចរាចរនៅ "ដោនថោន"ក៏នឹងស្ទះចរាចរនៅ"ខលី"ដែរ...តែ




ទីធ្លាដ៏ធំទូលាយនិងស្រស់ស្អាតអាចក្លាយទៅជាវិទ្យាល័យឡូវែល នៅខលី

រឿងនេះខ្ញុំយល់ថា យើងនៅមាន៤-៥ឆ្នាំដែរសម្រាប់ពិចារណាកែរលំអពីការស្ទះចរាចនៅទីនោះ...

**ខ្មែរផុសស.រ.អាះ** មានខ្លះនិយាយថា គេនឹងចំណាយលុយច្រើនសម្រាប់ដឹកជញ្ជូនសិស្សទៅ "ខលី" មែនទេ?

**ដាន់ រូកៈ** គេនឹងមានគម្រោង២សម្រាប់ការដឹកជញ្ជូននេះ គឺគេដាក់ "ស្គូលប៊ើស" ចំនួន




ក្រុមគ្រួសារពលរដ្ឋនៅប៊ែលវើឌៀ

៤២សម្រាប់ដឹកសិស្សដែលនៅតំបន់ខុសៗគ្នាដោយត្រូវចំណាយ៣លានក្នុងមួយឆ្នាំមិនមាននរណាត្រូវចេញថ្លៃដឹកជញ្ជូនរដ្ឋនោះទេ គឺជាលុយពន្ធគេដឹកសិស្សចែកទៅតំបន់ចំនួន៥នៅជុំវិញឡូវែលនេះ នឹងម្យ៉ាងទៀតគេអាចប្រើរថយន្តក្រុងដែលបង់តម្លៃយ៉ាងថោក...

**ខ្មែរផុសស.រ.អាះ** ការដឹកជញ្ជូននេះទៀតសោត គឺជាបញ្ហាសន្តិសុខរបស់កុមារនឹងយុវជនគេមិនគួរឱ្យសិស្សដើរកាត់ក្រុងយ៉ាងឆ្ងាយរបៀបនេះទេ, នៅតាមផ្លូវ មានបញ្ហាធ្លាក់ភ្លៀង-ធ្លាក់ខ្យល់ ឬធ្លាក់ទឹកកកបន្ថែមដោយបញ្ហាជនអាក្រក់ចាំធ្វើបាបក្មេងនៅកណ្ដាលក្រុងទៀត ហេតុអ្វីបានមិនចាត់ទុកថា ដាក់ក្មេងក្នុងរថយន្តសាលាជាបញ្ហាចាំបាច់?

**ដាន់ រូកៈ** យើងអ្នករស់នៅក្នុងឡូវែលជាអ្នកបង់ពន្ធ ដឹងហើយថា "ក្មេងមិនគួរដើរទៅសាលាទេទោះជាចម្ងាយណាក៏ដោយ"ដោយសារតែបញ្ហាថា "ក្មេងមានសិទ្ធនឹងទទួលការសិក្សាដ៏ប្រសើបំផុត ដើម្បីនឹងធ្វើឱ្យបានគេត្រូវតែជូនដំណើរក្មេងឱ្យទៅដល់សាលរៀន" យើងបានចេញថ្លៃសម្រាប់ដាក់រថយន្តសាលាដឹកក្មេងទៅរៀនដាក់រថយន្តសង្គ្រោះបន្ទាន់ដោយមិនមានឱ្យបង់ថ្លៃ ក៏ព្រោះតែបញ្ហាសន្តិសុខនឹងការសិក្សារបស់ក្មេងនេះ...

**ខ្មែរផុសស.រ.អាះ** បើនិយាយពីសំណង់វិញ អ្នកចូលចិត្ត"ដោនថោន"ថា"ឡូវែលបើនឹងប្តូរទីតាំងទៅ"ខលី"នឹងចំណាយប្រាក់ច្រើន ហើយនោះវាជាទម្ងន់ដល់អ្នកបង់ពន្ធ!

**ដាន់ រូកៈ** "ខលី"គឺជាជម្រើសលេខ៤ មានតម្លៃ៨.៨លាន ដែលសាលាក្រុងត្រូវខ្ចីប្រាក់បន្ថែម, សម្រាប់អ្នកបង់ពន្ធនឹងបង់បន្ថែម១៨ដុល្លាក្នុងមួយឆ្នាំ, បើធ្វើនៅ"ដោនថោន"ក៏យើងត្រូវចេញប្រាក់១២ដុល្លាលើសក្នុងមួយឆ្នាំដែរក្នុងជម្រើសសំណង់ក្នុងក្រុងលេខ៥, ដែលសំខាន់នោះ ថា "តើយើងចង់បានវិទ្យាល័យមួយដែលថ្មីស្រឡាង១00% សង់ស្របតាមបច្ចេកទេសទំនើបបំពាក់សម្ភារៈថ្មីសិស្សរៀនក្នុងបរិយាកាសនៃសតវត្សទី២១ សិស្សអាចរកអនាគតរបស់ខ្លួនឃើញ ឬមួយក៏ចង់បានវិទ្យាល័យដែលថ្មីតែ៨0% នៅកន្លែងដែលមិនអាចសម្របទៅនឹងបច្ចេកទេសនាការសិក្សាសម័យថ្មីបាន?

**ខ្មែរផុសស.រ.អាះ** តាមដែលខ្ញុំសង្កេតទៅកាលពីដំបូងមិនសូវមានអ្នកការពារឱ្យវិទ្យាល័យប្តូរទៅទីតាំងចេញ"ខលី"ទេ តែដោយមានការពន្យល់គ្នាដោយបានឃើញទីតាំងរបស់"ខលី" មានមនុស្សកាន់តែច្រើនឡើង គាំទ្រឱ្យវិទ្យាល័យប្តូរទៅ"ខលី"វិញ នេះប្រហែលជាប្រជាពលរដ្ឋត្រូវការពេល ដើម្បីឱ្យមានការពន្យល់ឱ្យបានជ្រួតជ្រាបច្បាស់លាស់សម្រាប់ធ្វើការសម្រេច?

**ដាន់ រូកៈ** សាលាក្រុងបានចេញទៅធ្វើការពន្យល់ច្រើនដងនៅកន្លែងផ្សេងៗបានធ្វើឱ្យមនុស្សមានការផ្លាស់ប្តូរយោបល់ខ្ញុំបានយកពេលទៅជជែកជាមួយ"ស៊ីប៊ីអេ" ជាមួយ "សមាគមខ្មែរ" ជាមួយ"ខ្មែរផុស"... ខ្ញុំបានឃើញមនុស្សជាច្រើននឹងកាន់តែច្រើនបានស្រឡាញ់"ខលី"យល់ឃើញថាវិទ្យាល័យរបស់គេគួរតែនៅទីនោះ...ពេលវេលាដែលសមាជិកក្រុមប្រឹក្សាក្រុងត្រូវសម្រេចនឹងមកដល់នៅថ្ងៃទី១៣នេះ ភារៈកិច្ចយើងត្រូវធ្វើ

តទៅទំព័រទី ២០

# LOWELL COMMUNITY HEALTH CENTER

## Caring for Lowell. Caring for You.

- **Metta Health Center - Primary Care**
  មណ្ឌលមេត្តាសុខភាព–មន្ទីរពេទ្យប្រចាំគ្រួសារ
- **Behavioral Health Services**
  កម្មវិធីសុខភាពផ្លូវចិត្ត
- **Teen Programs**
  កម្មវិធីសម្រាប់យុវវ័យ
- **Domestic Violence Program**
  កម្មវិធីអប់រំផ្នែកអំពើហឹង្សាក្នុងក្រុមគ្រួសារ
- **Help applying for health insurance**
  កម្មវិធីជំនួយដាក់ពាក្យសុំការធានារ៉ាប់រងសុខភាព
- **Services in Khmer, Laotian, Burmese, & Nepalese**
  កម្មវិធីបំរើផ្សេងៗ ជាភាសាខ្មែរ ឡាវ ភូមា និងនេប៉ាល់



**PHARMACY | ឳសថស្ថាន**

Pharmacy hours:
Monday - Friday 8am - 9pm
Saturday - 8:30am - 2:30pm

**135 & 161 Jackson Street, Lowell | 978.441.1700 | www.lchealth.org |**

---

# *For your special day...*

# សម្រាប់ថ្ងៃដ៏ពិសេសរបស់អ្នក

**The UMass Lowell Inn & Conference Center** provides timeless, modern elegance with a relaxing atmosphere.

You and up to 450 guests will be catered to by our attentive staff, while you celebrate in style and comfort.

We offer overnight lodging, scenic outdoor photo opportunities, and a variety of ceremony spaces, including smaller rooms for showers, rehearsal dinners, and engagement parties.

All of our menus can be personalized to suit your individual needs.



**សណ្ឋាគារ យូម៉ាសឡូវែលនឹងមណ្ឌលប្រជុំ**

ផ្តល់ជូនយ៉ាងទាន់ចិត្ត ជឿនលឿន សង្ហា ជាមួយនឹងបរិយាកាសយ៉ាងរំភើយ

លោកអ្នកនឹងភ្ញៀវរហូតដល់៤៥០នាក់អាចនឹងជប់លៀង ដោយមានការយកចិត្តទុកដាក់ពីបុគ្គលិកយើង នៅពេលដែលលោកអ្នកកំពុងរៀបពិធី ប្រកបដោយសម្បូរបែបនឹងយ៉ាងកក់ក្តៅ ។

យើងផ្តល់ជូនការស្នាក់អាស្រ័យឆ្លងរាត្រី, ទីធ្លាខាងក្រៅគួរឲ្យរំភើបសម្រាប់ មានឱកាសថតរូបនឹងបន្ទប់សម្រាប់ពិធីការគ្រប់ធុន,

រាប់ទាំង បន្ទប់តូច សម្រាប់បង្កក់កូន, ត្រៀមសម្រាប់ជប់លាងអាហារពេលល្ងាចនឹងពិធី ភ្ជាប់ពាក្យ...។

គ្រប់បញ្ជីមុខម្ហូបអាចនឹងរៀបចំជូនស្របតាមតម្រូវការរបស់បុគ្គលម្នាក់ៗបាន ។

UMASS LOWELL
Inn & Conference Center

**UMass Lowell Inn & Conference Center**
50 Warren St., Lowell MA 01852 978-934-6920 877-886-5422 **www.uml.edu/icc**

# សកម្មភាពចុងក្រោយរបស់ប្រធានាធិបតី ឌុណាលត្រម នៅសេដ្ឋវិមាន

**ដោយ ពិន សំខុន**

**១-សហរដ្ឋអាមេរិកដកខ្លួនចេញពី "កិច្ចព្រមព្រៀងក្រុងប៉ារីសស្តីពីកំដៅ"**

លោកប្រធានាធិបតី ឌុណាល ត្រម បានប្រកាសដកខ្លួនចេញពី"កិច្ចព្រមព្រាងក្រុងប៉ារីសស្តីពីកំដៅ"កាលពីរសៀលថ្ងៃទី២មិថុនា២០១៧។ គឺជាកិច្ចព្រមព្រៀងដែលផ្តល់ជាសន្និសិទធំ៧នឹងមុខមាត់ដល់ប្រទេសធំៗ ជាពិសេសទៅទៀតនោះ ជាទីផ្សារថ្មីដ៏ធំមួយសម្រាប់ប្រទេសជឿនលឿនបញ្ចេញផលិតផលរបស់ប្រើប្រាស់ទំនើបទាក់ទងទៅនឹងការថែររក្សាបរិដ្ឋានមានរដ្ឋយន្តប្រើអគ្គិសនីមានបន្ទះ"សូឡា" ឬបច្ចេកវិទ្យាសន្សំថាមពលផ្សេងៗ។

កិច្ចព្រមព្រៀងក្រុងប៉ារីសស្តីពីកំដៅនេះ មានប្រទេស១៩៥ បានចុះហត្ថលេខា ហើយសន្យាគ្នាថានឹងនាំគ្នាធ្វើយ៉ាងណាកុំឱ្យកំដៅពិភពលោកឡើងលើសពីកំរិតធម្មតា១,៥អង្សា ដែលអ្នកវិទ្យាសាស្ត្រព្យាករណ៍ថា ពិភពលោកអាចនឹងវិលលឿនខុសប្រក្រតីបង្កើនខ្យល់ព្យុះច្រើននឹងបង្កើនព្រឹត្តការណ៏ធម្មជាតិដែលអាចបង្ករជាគ្រោះថ្នាក់ពិភពលោកមិនអាចគ្រប់គ្រងបាននៅឡើយ... ប្រសិនបើមិនពួតដៃគ្នាទប់ស្កាត់ការកើនកំដៅក្នុងពិភពលោកនេះទេ។

លោកប្រធានាធិបតី ឌុណាល ត្រម មិនបានជឿលើការកើនកំដៅផែនដីនោះទេ លោកថា គឺជាព្រឹត្តការធម្មជាតិ ហើយការជឿទៅលើព្រឹត្តការនេះនាំឱ្យសហរដ្ឋអាមេរិកខាតបង់ប្រាក់រាប់ពាន់លានដុល្លាចំណាយយ៉ាងឥតប្រយោជន៏ទៅបរទេសដែលសហរដ្ឋអាមេរិកត្រូវឈប់ចំណាយ


លោកប្រធានាធិបតី ឌុណាល ត្រម នៅពេលទៅទស្សនកិច្ចនៅសភាអឺរ៉ុប


លោកប្រធានាធិបតី ឌុណាល ត្រម

លុយដ៏ឥតប្រយោជន៏នេះតទៅទៀត។ លោកបន្តថា បើចង់ឱ្យអាមេរិកាំងនៅក្នុងកិច្ចព្រមព្រៀងនោះតទៅទៀត ត្រូវមានការចរចារសារជាថ្មីដើម្បីបញ្ចុះតម្លៃសម្រាប់ចំណាយថវិការរបស់សហរដ្ឋអាមេរិកបានន័យថា បានន័យថា សហរដ្ឋអាមេរិក "មិនប្រឆាំងនឹងចលនាកំដៅផែនដីទេ" តែដកខ្លួនដើម្បីចរចាគ្នាសាជាថ្មី។

ប្រធានាធិបតីនៃប្រទេសអាល្លឺម៉ង់ប្រទេសបារាំងបានសម្តែងការខកចិត្តចំពោះឥរិយាបទនៃសហរដ្ឋអាមេរិក បានអង្វរករកុំឱ្យសហរដ្ឋអាមេរិកដកខ្លួនចេញពីសន្ធិសញ្ញានេះ តែលោក ឌុណាល ត្រម មិនបានយល់ព្រមទេ -ពួកគេ (រួមទាំងឥណ្ឌាអង់គ្លេសផងចុក៏មិនព្រមឱ្យសហរដ្ឋអាមេរិកតែរប្រែ ឬប្តូរអត្ថន័យអ្វីមួយក្នុងកិច្ចព្រមព្រៀងរបស់ពួកគេទេ ហើយការដកខ្លួនចេញពីកិច្ចព្រមព្រៀងស្តីពីសីតុណ្ហភាពពិភពលោកនេះ បានធ្វើឱ្យសហរដ្ឋអាមេរិកនៅឯកោតែម្នាក់ឯងឆ្ងាយពីសហភាពអឺរ៉ុប សហគមន៏អាស៊ី នឹងអូសេអានី អស់រលីង -មិនតែប៉ុណ្ណោះ នៅសហរដ្ឋអាមេរិកនេះ នៅមានរដ្ឋខ្លះដែលគេមានជំនឿលើអ្នកវិទ្យាសាស្ត្រស្តីពីវិបត្តិនៃការកើនកំដៅពិភពលោកនេះ មិនបានផ្តាច់ខ្លួនចេញពីសន្ធិសញ្ញានេះទេ ដូចជានៅរដ្ឋញូយ៉ករដ្ឋម៉ាសាឈូសិត នឹងរដ្ឋកាលីហ្វ័រញ៉ាជាដើម។

**២-សហរដ្ឋអាមេរិកនឹង"ណេតូ"**

នៅពេលទស្សនកិច្ចរបស់ប្រធានាធិបតីត្រមនៅសហភាពអឺរ៉ុប ប្រធានាធិបតីសហរដ្ឋអាមេរិកបានជួបប្រស្រ័យជាមួយអគ្គការ"ណេតូ-NATO" ដែលជាអង្គការពិភពលោកដ៏សំខាន់មួយកើតពីឆ្នាំ១៩៥៣នៅ"ហ្វុងតែនប្លូ"ប្រទេសបារាំង សម្រាប់ចងសម្ព័ន្ធកម្លាំងទ័ពបក្សសម្ព័ន្ធនៅអឺរ៉ុបកណ្តាលសម្រាប់កាពារអឺរ៉ុបនឹងអាមេរិក ដោយសារមានសហរដ្ឋអាមេរិកជាសមាជិកម្នាក់ដែរ -១០ឆ្នាំក្រោយមកអង្គការនេះបានប្តូរទីតាំងទៅប្រទេសបែលហ្សិកវិញរហូតដល់សព្វថ្ងៃ ដោយបារាំងនៃលោកប្រធានាធិបតី ដឺហ្គោល មិនចង់ឃើញទ័ពបរទេសនៅក្នុងប្រទេសខ្លួន។

នៅពេលទៅធ្វើទស្សនៈកិច្ចរបស់ប្រធានាធិបតីចុងក្រោយបង្អស់ ឌុណាល ត្រម បានទាមទារឱ្យប្រទេសទាំង២៩ជាសមាជិក"ណេតូ"បង់វិភាគទានរបស់ខ្លួន ក្នុងនោះមានប្រទេសតែ៤ទេដែលបានបំពេញភារៈកិច្ចនេះ គឺអាមេរិកបង់វិភាគទាន៧៣% បន្ទាប់មកមានប្រទេសអាល្លឺម៉ង់, បារាំង, នឹងអង់គ្លេស ដែលបានបង់វិភាគទានដែលនៅសល់។ លោកប្រធានាធិបតី ឌុណាល ត្រម បានទាមទារយ៉ាតឹងតែងឱ្យប្រទេសទាំង២៩បង់វិភាគទានរបស់ខ្លួនតែប្រទេសទាំងនោះបាននិយាយថា "គេឥតមានជំពាក់វិភាគទានអ្វីចំពោះអាមេរិកាំងទេ" ដែលជាហេតុធ្វើឱ្យទំនាក់ទំនង"ណេតូ-អាមេរិកាំង" ក្លាយជាត្រជាក់ស្រឹប, ហេតុអ្វីក៏មានរឿងយ៉ាងនេះ ?

**តទៅទំព័រទី ០៨**







តមកពីទំព័រទី ០១ **បោះឆ្នោតឃុំសង្កាត់: នៅតិចជាង៥%ទៀត...**

គណបក្សសង្គ្រោះជាតិបានកើនចំនួនឃុំសង្កាត់បានច្រើនគួរឱ្យកត់សំគាល់ គឺលើសពីចំនួន៤០ឃុំសង្កាត់កាលពី៥ឆ្នាំមុនចំនួន១២ដង។

**តើលទ្ធផលនេះមានន័យយ៉ាងណា?**

គ.ជ.ប.ទស្សនៈជាច្រើនបានកោតសសើរដល់គ.ជ.ប.លើកនេះថា"បានធ្វើឱ្យលទ្ធផលនៃការបោះឆ្នោតថ្ងៃទី៤ មិថុនានេះ មានលក្ខណៈប្រសើរជាងមុន ដែលអាចធ្វើឱ្យមានការចុះសម្រុងគ្នារវាងគណបក្សប្រកួតគ្នាលើការប្រកាសលទ្ធផលដែលបានចេញមក"។ គណបក្សប្រឆាំងដែលមានសមាជិករបស់ខ្លួននៅក្នុងគ.ជ.ប.ថ្មីជាមួយគ្នានឹងគណបក្សប្រជាជនដែរនោះ បានប្រគល់សេចក្តីសង្ឃឹមនឹងទទួលបានលទ្ធផលត្រឹមត្រូវ ហើយទទួលស្គាល់ដែរថា "គ.ជ.ប.លើកនេះប្រសើរជាងលើកមុនដែលកាន់កាប់ដោយគណបក្សប្រជាជនតែម្នាក់ឯង"។ មកទល់ត្រឹមនេះប្រាកដជាផលចំណេញសម្រាប់ប្រជាជាតិក្នុងដំណើរទៅរកលទ្ធិប្រជាធិបតេយ្យបានមួយដំណាក់ការហើយ ថ្វីត្បិតតែនៅសល់ដំណាក់ការច្រើនទៀតដែលត្រូវឆ្លងកាត់ក៏ដោយ។ បញ្ជីបោះឆ្នោតថ្មីក៏មានលក្ខណៈត្រឹមត្រូវជាងលើកមុន ហើយមានអ្នកចុះឈ្មោះបោះឆ្នោតសរុបចំនួន៧.៨៦៥,០៣៣នាក់ ក្នុងចំណោមប្រជាពលរដ្ឋខ្មែរទាំងអស់ចំនួន ១៥.៧២១.៣៦៦នាក់ ហើយអ្នកដែលបានចេញទៅបោះឆ្នោតមានចំនួន៦.៧៤៣.៣២៩ ត្រូវជា៨៥,៧% គឺជាចំនួនដែលច្រើនបំផុតលើសពី៥ឆ្នាំមុន១.៧លាននាក់ ។

លទ្ធផលបណ្តោះអាសន្នរបស់គណបក្សសង្គ្រោះជាតិ គឺឈ្នះបានមេឃុំនឹងចៅសង្កាត់ប្រមាណ៤៨៦ ក្នុងចំណោមឃុំសង្កាត់ទាំងអស់១៦៤៦ ក៏ប៉ុន្តែទទួលបានសន្លឹកឆ្នោតទាំងអស់៤៥%(តាមសេចក្តីរាយការរបស់នីហ្វេក) នៃចំនួនអ្នកបោះឆ្នោត។ ថ្វីត្បិតតែគណបក្សសង្គ្រោះជាតិមានសេចក្តីសង្ឃឹមខ្ពស់ជាងលទ្ធផលនេះក៏ដោយ ក៏គេអាចវិភាគឃើញថា: ១-គណបក្សសង្គ្រោះជាតិទើបនឹងកើតនៅឆ្នាំ២០១៣ ដូច្នេះមិនទាន់មានមូលដ្ឋានជនបទរឹងមាំនៅឡើយទេ បើប្រៀបទៅនឹងគណបក្សប្រជាជនកម្ពុជា ហើយគណបក្សនេះទើបនឹងដាក់បេក្ខជនបានគ្រប់កន្លែងដល់ជនបទបាននៅ២-៣ខែមុននេះតែប៉ុណ្ណោះ ២-សម្លេងគណបក្សតូចៗទាំងអស់មាន១០ ដែលចូលមកប្រកួតប្រជែងដែរនោះ ច្រើនបំបែកសម្លេងតែពីគណបក្សសង្គ្រោះជាតិតែប៉ុណ្ណោះ៣-សម្លេងឆ្នោតរបស់កម្មករ-កម្មការិនីរាប់ម៉ឺនសែននាក់ មិនបានត្រូវគេយកចិត្តទុកដាក់ខ្ពស់ទេ ពួកគេមិនអាចបោះឆ្នោតនៅទីកន្លែងធ្វើការបានទេត្រូវទៅបោះនៅភូមិកំណើត ដែលមួយចំនួនទៅស្រុកមិនបានដោយនៅឆ្ងាយពេក នេះក៏ព្រោះខាងរដ្ឋាភិបាលយល់ថា ពួកកម្មករទាំងនោះច្រើនបោះឆ្នោតឱ្យគណបក្សសង្គ្រោះជាតិ៤-កម្មករចំណាកស្រុករាប់ម៉ឺនសែននាក់ទៀត ក៏មិនអាចត្រឡប់មកបោះឆ្នោតបានដែរ ។ គណបក្សសង្គ្រោះជាតិថ្លែងថា -ប្រជាពលរដ្ឋប្រមាណ២លាននាក់ មិនអាចបោះឆ្នោតបានដោយសារចុះឈ្មោះក្នុងបញ្ជីមិនទាន់ -ម្យ៉ាងទៀតគណបក្សខ្លួនបានរងការគម្រាមកំហែងពីសំណាក់រដ្ឋាភិបាលជាប្រចាំតាំងពីឆ្នាំ២០១៥មក -បន្ថែមពីលើនេះនៅមានការគម្រាមសម្លាប់មនុស្សពីសំណាក់នាយករដ្ឋមន្ត្រីនិងគម្រាមបង្ក្រាបពីរដ្ឋមន្ត្រីកាពារជាតិនៅមុនពេលបោះឆ្នោតធ្វើឱ្យបរិយាកាសបោះឆ្នោតប្រកបដោយការភ័យខ្លាច -គណបក្សសង្គ្រោះជាតិថ្លែងបន្ថែមថា: វិទ្យុ នឹងទូរទស្សន៍រដ្ឋាភិបាលមិនបានគោរពតាមការណែនាំរបស់គ.ជ.ប.ទេ ក្នុងរយពេលឃោសនាមុនពេលបោះឆ្នោតនោះ។ យោងតាមស្ថារតីមិនស្មើភាពគ្នានឹងការរងគំនាបរបស់គណបក្សសង្គ្រោះជាតិយ៉ាងនេះហើយក្តីនៅតែទទួលបានលទ្ធផលបានឈ្នះជិត៥០០ឃុំសង្កាត់ដែរ នោះគឺជាជោគជ័យដ៏ត្រចះត្រចង់របស់សង្គ្រោះជាតិដែលបានធ្វើឱ្យប្រជាពលរដ្ឋជឿងាកមកគាំទ្រ "គណបក្សដែលរងគ្រោះដោយរដ្ឋាភិបាលខ្លួនឯង" ក្នុងចំនួនច្រើនហួសការប៉ាន់ស្មាន។

លទ្ធផលបណ្តោះអាសន្នរបស់គណបក្សប្រជាជនកម្ពុជាគឺឈ្នះបានមេឃុំនឹងចៅសង្កាត់ជាង១១៥៩ដែលមានចំនួនអ្នកបោះឆ្នោតឱ្យ៤៨% (តាមសេចក្តីរាយការរបស់នីហ្វេក) ជាចំនួនដែលថយចុះ បើប្រៀបទៅនឹងកាលពី៥ឆ្នាំមុន ដែលបានឈ្នះលើ១៥៨០ឃុំសង្កាត់។ ចាប់តាំងពីគណបក្សសិទ្ធិមនុស្សនឹងគណបក្សសមរង្ស៊ីចាប់ដៃគ្នាបង្កើតបានជាគណបក្សសង្គ្រោះជាតិពេលណាមកគណបក្សប្រជាជនកម្ពុជាបានមើលឃើញថា ជាការគម្រាមកំហែងយ៉ាងខ្លាំងក្លាដល់ការរក្សាអំណាចរបស់ខ្លួន ម្ល៉ោះហើយតាមរយៈអំណាចលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បុរសខ្លាំងរូបនេះបានប្រើមធ្យោបាយរដ្ឋគ្រប់យ៉ាងទាំងស្របច្បាប់ទាំងក្រៅច្បាប់ ដើម្បីរំលាយសម្ព័ន្ធភាពរំលាយមេគណបក្សនឹងរំលាយគណបក្សប្រឆាំងឱ្យទាល់តែបានសម្រេច: មានតាំងពីការប្រកាសលទ្ធផលខុសច្បាប់នៃការបោះឆ្នោតឆ្នាំ២០១៣,មានការបន្ទន់ឥរិយាបទចរចាបន្ទាប់ពីបោះឆ្នោត, មានបង្កើតវប្បធម៌សន្ទនា ហើយរំលាយទៅវិញ, មានបណ្តឹងឧក្រិដ្ឋលើ សម រង្ស៊ី ពីរឿងបរិហាកេរ្តិ៍មានការប៉ុនប៉ងចាប់ខ្លួន កឹម សុខា ពីរឿងស្រីញី, មានការចាប់ខ្លួនដាក់គុកមន្ត្រីអភ័យឯកសិទ្ធនឹងមន្ត្រីសិទ្ធមនុស្ស, បង្កើតច្បាប់ដែលអាចរំលាយគណបក្សប្រឆាំងបាន,...រួមសេចក្តីទៅលោក ហ៊ុន សែន គ្មានពេលវេលានឹងគិតពីបញ្ហាជាតិទេ គឺគិតតែពីបញ្ហាអាយុជីវិតនៃអំណាចគាត់តែមួយប៉ុណ្ណោះ។ ហេតុអ្វីបានជាលោក ហ៊ុន សែន នៅរក្សាឃុំសង្កាត់បានទៅដល់ជាង១១៥០នោះបាន? យើងបានតាំងសំនួរពីមុននេះបន្តិចមកហើយថា"គណបក្សប្រជាជននៅស្ងៀមស្ងាត់មុនពេលបោះឆ្នោតយ៉ាងនេះ ទំនងជាមានល្បិចអ្វីផ្សេងដែលយើងនឹកមិនទាន់ដល់ក៏មិនដឹង!" ល្បិចនោះគឺគណបក្សប្រជាជន គេមានបណ្តាញមូលដ្ឋានគេប្រមាណជា២-៣លាននាក់ នៅទូទាំងប្រទេសដែលគេរក្សាដែរមិនឱ្យរបូតពីដៃទេ បោះឆ្នោតពេលណា ក៏មានឆ្នោត២-៣លាននាក់សម្រាប់គាំទ្រគេដែរ ។សម្លេងឆ្នោតនោះ បូករួមទាំងសម្លេងបំបែកបក្សប្រឆាំងបូករួមទាំងសម្លេងគម្រាមកំហែងរបស់រដ្ឋាភិបាលនឹងឡើងកាន់តែខ្ពស់នៅពេលអ្នកមិនទៅបោះឆ្នោតមានកាន់តែច្រើនឡនៅពេលដែលសម្លេងអ្នកទៅបំបែកបក្សប្រឆាំងនោះ ក៏មានគេចូលចិត្តច្រើន, នៅពេលដែលរាស្ត្រនៅជនបទភ័យព្រួយពីសុវត្ថិភាពគ្រួសារខ្លួន នៅពេលខ្លួនចូលចិត្តបក្សប្រឆាំងទាំងនេះហើយដែលជាទំនប់មិនឱ្យសង្គ្រោះជាតិឡើងខ្ពស់ជាងនេះបាននៅឡើយ។

ទេសភាពនយោបាយថ្មីបន្ទាប់ពីបោះឆ្នោតឃុំសង្កាត់រួចអ្នកវិភាគយល់ថា"ការបោះឆ្នោតឃុំសង្កាត់នេះវានឹងជះឥទ្ធិពលទៅលើការបោះឆ្នោតសាកលនាខែកក្កដាឆ្នាំ២០១៨ខាងមុខ"ជាមិនខាន ។ មែនហើយជាមួយនឹងឃុំសង្កាត់ជិត៥០០របស់ខ្លួនគណបក្សសង្គ្រោះជាតិអាចពង្រីកបាន


កញ្ញា សុិន រ៉ូសិត ទើបនឹងជាប់ជាមេឃុំ នៅឃុំអូរចា

មូលដ្ឋានកាន់តែធំកាន់តែសំខាន់ជាងមុនយ៉ាងតិចក៏១២ដងដែរ... ជាពិសេសទៅទៀតនោះ បើគិតម្យាងទៀត យកចំនួនភាគរយនៃអ្នកបោះឆ្នោតមកប្រើទៅវិញ,គឺគណបក្សសង្គ្រោះជាតិបានឃុំសង្កាត់តិចមែន ប៉ុន្តែចំនួនអ្នកបោះឆ្នោតតិចជាងគណប្រជាជនកម្ពុជាតែ៣-៤% តែប៉ុណ្ណោះ, វាដូចជាគណបក្សសង្គ្រោះជាតិបានឆ្នោតប្រមាណជា៥០%សម្រាប់ការបោះឆ្នោត២០១៨រួចជាស្រេច។ នេះហើយដែលចំណេះគណបក្សប្រជាជនជិះកខ្លួនឯង លាក់គេមិនជិតទេ ប្រើល្បិចចែកឃុំសង្កាត់ដើម្បីបានចំនួនច្រើនមកខាងខ្លួន តែចំនួនអ្នកបោះឆ្នោតនៅលើគោកបានបង្ហាញថា ខុសគ្នាតែតិចជាង៥%សោះ, បើក្នុងរូបភាពប្រកួតមិនស្មើភាពគ្នាដូចពេលនេះ "គណបក្សសង្គ្រោះជាតិគួរចាត់ទុកខ្លួនឯងថាឈ្នះឆ្នោតនោះបាត់ទៅហើយ"។

បើគណបក្សប្រជាជនមិនប្តើមមើលការពិតឱ្យចំមុខពេលនេះទេ ហើយផ្តើមធ្វើសកម្មភាពរក្សានិរន្តភាពរបស់ខ្លួនចរចារជាមួយសង្គ្រោះជាតិរករូបមន្តដើម្បីរស់បន្តទៅទៀតទេ នៅតែមួយឆ្នាំទៀតតែប៉ុណ្ណោះគណបក្សនេះអាចនឹងរលាយបាន មិនថាខ្លួនចង់ក្រាញអំណាចទៅរួចនោះទេ។ សូមមើលតែប៉ុណ្ណោះថា គណបក្សប្រជាជនចង់សម្លាប់គណបក្ស"ជាតិខ្មែរ" ចង់សម្លាប់គណបក្ស "សមរង្ស៊ី" ចង់សម្លាប់គណបក្ស "សង្គ្រោះជាតិ" ចង់បុន្មានឆ្នាំហើយ? តែស្រមោលនៃការប្រឆាំងដ៏រឹងមាំនៅតែអន្ទោលតាមប្រាណអ្នកដដែល, បន្ទាប់ពីឆ្នាំ២០១៣មកទៀត ចង់សម្លាប់គណបក្ស "សង្គ្រោះជាតិ"ចង់សម្លាប់"សម រង្ស៊ី" ចង់សម្លាប់ "កឹម សុខា" តែស្រមោល សម រង្ស៊ី ស្រមោល "សង្គ្រោះជាតិ"នៅតែលងអ្នកទាំងកណ្តាលថ្ងៃមិនព្រមទៅណាសោះ! គួរឆ្ងល់ដែរឬទេថា ហេតុអ្វីបានអាត្មាអញ មានអ្វីៗទាំងអស់ហើយបែរជាទៅចាញ់គណបក្សសង្គ្រោះជាតិដ៏កំព្រកនោះទៅវិញ? បើឆ្លើយនឹងសំនួរនេះរួចអ្នកនឹងដឹងថាចំណុចស្លាប់របស់អ្នកមាន៣យ៉ាង គឺ១-សម្លាប់ខ្លួនឯងដោយក្តីឈឺចាប់ក្នុងចិត្ត ២-ស្លាប់ដោយសារអ្នកមានទោស ព្រោះបានប្រព្រឹត្តអំពើឧក្រិដ្ឋច្រើនពេក ៣-ស្លាប់ដោយរឹងរៃ ដូចក្រុមខ្មែរក្រហម ឬហ្វុនស៊ិនប៊ិច ដោយគ្មានអ្នកគាំទ្រ។

ឃើញលោក កឹម សុខា ខិតខំពុះពារដឹកនាំការឃោសនាសង្គ្រោះជាតិតែម្នាក់ឯងមែន តែស្រមោលលោក សម រង្ស៊ី ថ្វីត្បិតតែគ្មានមុខងារជាប្រធានបានត្រូវម្ចាស់ឆ្នោតឃើញថា នៅជាមួយគ្នាជានិច្ចនេះជាកម្លាំងបំបែកមិនបាននៃសង្គ្រោះជាតិ, ដែលលោក ហ៊ុន សែន ព្យាយាមបំបែកខ្លាំងណាស់តែធ្វើមិនបាន។ ខែមិថុនា២០១៧ចម្ងាយផ្លូវនៅតែតិចជាង៥%នៃលទ្ធផលផ្លូវការទៀតប៉ុណ្ណោះ សង្គ្រោះជាតិនៃ"កឹម សុខា-សម រង្ស៊ី" នឹងទៅដល់គោលដៅកាន់អំណាចប្រទេសនាខែកក្កដា២០១៨ ក្នុងឱកាសបោះឆ្នោតសាកល្ប, ជាមួយនឹងសង្គ្រោះជាតិចេះតែឡើង រីឯគណបក្សប្រជាជនចេះតែចុះជាមួយនឹងការចុះឈ្មោះបោះឆ្នោតបន្ត(ប្រមាណ២លាននាក់)ទៅទៀតនោះ, គណបក្សប្រជាជនកម្ពុជាដឹងខ្លួនជាងនរណាទាំងអស់ ថាខ្លួនមុខជានឹងត្រូវប្រជាពលរដ្ឋ"បរាមុខ" គេនឹងប្តូរអ្នកកាន់អំណាចចាស់ចេញឱ្យទាល់តែបាន មិនថាមានគម្រាមថា"មានសង្គ្រាម ឬអត់" នោះទេ។

យើងគួរមានមោទនភាពណាស់ នឹងឃើញប្រជាពលរដ្ឋខ្មែរ កំពុងកាន់វាសនាកម្ពុជាដោយខ្លួនឯងយ៉ាងច្បាស់លាស់នឹងរឹងមាំ។ សន្លឹកបោះឆ្នោតលើកនេះ បានបង្ហាញពីភាពចាស់ទុំជាម្ចាស់ឆ្នោត,គេសម្រេចចិត្តដើរទៅមុខមួយៗតែមិនរួញរា, គ្មានការភូតកុហកណាមួយអាចកន្លងពីភ្នែកអ្នកទាំងនោះទេ, គេអាចទាក់ទងគ្នាឆ្លងទ្វីបបាន, គេអាចស្វែងរកមិត្តដែលអាចជួយគ្នាក្នុងគ្រាក្រ ជាពិសេសទៅទៀតនោះម្ចាស់ឆ្នោតមិនបានភ្លេចគុណដល់អ្នកស្នេហាជាតិ ដែលធ្លាប់បានតស៊ូ ដើម្បីគាំទ្រពួកគេទេនេះជារូបភាពនៃតម្លៃពលរដ្ឋអារីយប្រទេស ថ្វីត្បិតតែពលរដ្ឋខ្មែរនៅក្រនឹងរងការគាបសង្កត់ខ្ពស់ក៏ដោយ -គ.ជ.ប.ថ្មី បានបង្កើនសមត្ថភាពខ្លួន ក៏បានបង្ហើបផ្លូវជួយឱ្យសាធារណជនបានឃើញសមត្ថភាពពលរដ្ឋខ្មែរដែលចេះគ្រប់គ្រងសន្លឹកឆ្នោតជាម្ចាស់វាសនាខ្លួនជាអ្នកសម្រេចយកគណបក្សដែលខ្លួនស្រឡាញ់បាន៕

តមកពីទំព័រទី ០៤

## សកម្មភាពចុងក្រោយរបស់ប្រធានាធិបតី...

នៅក្នុងលក្ខន្តិករបស់"ណេតូ"វិភាគទាននេះមានបង់"ដោយចំពោះ"នឹង"មិនចំពោះ"នឹងទៅតាមធនធាននៃប្រជាពលរដ្ឋរបស់ប្រទេសខ្លួនថែមទៀត, សហរដ្ឋអាមេរិកជាប្រទេស"អ្នកមាន"នឹងបង់វិភាគទានច្រើនជាងគេរហូតដល់២២% អាល្លឺម៉ង់១៤%បារាំង១១%នឹងអង់គ្លេស១០%, រីឯប្រទេសអឺរ៉ុបឯទៀតៗបង់វិភាគទាននេះតិចតួចបំផុត(ពី១-៥%)ខ្លះទៀតដូចជាប្រទេសដែលទើបនឹងចេញពីនឹមកុម្មុនិស្តឥតមានបង់វិភាគទាននេះទេ តែបានជួយជាកម្លាំង"ណេតូ"ពីប្រទេសរបស់ខ្លួនបានច្រើនណាស់ដែរ។ ករណីវាយនៅប្រទេស"អ៊ីរ៉ាក់"អាមេរិកបានប្រើយន្តការ "ណេតូ" ទាំងស្រុងតែប្រទេសបារាំងនឹងអាល្លឺម៉ង់ឥតមានដំណាងវាយអ៊ីរ៉ាក់ទេ ដូច្នេះអាមេរិកជាអ្នកចេញចំណាយលើសង្គ្រាមនេះ ទាំងមូលមានតែប្រទេស "អារាប៊ីសាអ៊ូឌីត"តែមួយប៉ុណ្ណោះ ដែលជួយគាំទ្រហិរញ្ញវត្ថុសហរដ្ឋអាមេរិកក្នុងចម្បាំងនេះ ពីព្រោះប្រទេសនេះត្រូវការការគាំទ្រយ៉ាងពេញទំហឹងពីសហរដ្ឋអាមេរិកវិញដែរ គេត្រូវតែ "ទិញសន្តិ



ភាព"ពីកម្លាំងទ័ពដែលគេជឿជាក់ពីសហរដ្ឋអាមេរិកនោះ។

ប្រសិនបើអាមេរិកមានបំណងដកខ្លួនពី "ណេតូ" មែន"ណេតូ"នឹងចុះខ្សោយ, សត្រូវអាមេរិកនឹងខិតចូលមកកាន់តែជិតហេតុនេះ ហើយបានជាសហរដ្ឋអាមេរិកបិទព្រំប្រទល់ដែនជាមួយប្រទេសអ៊ិស្លាមប្រទេស"មិកស៊ិក" ដើម្បីបង្កើនកិច្ចការពារប្រទេសខ្លួនដោយខ្លួនឯង, សហរដ្ឋអាមេរិកបាន"បន្ថយកម្លាំងការពារសន្តិសុខ"របស់ប្រទេសខ្លួនដោយការ"បន្ថយចំណាយ"។

### ៣-ប្រធានាធិបតី ឌុណល ត្រមនាយក "អេហ្វប៊ីអាយ"ជេម ខូមី

លោក ជេម ខូមី ជានាយក "អេហ្វប៊ីអាយ" តែងតាំងដោយប្រធានាធិបតី បារ៉ាក់អូបាម៉ា នៅឆ្នាំ១៩១៣ ហើយត្រូវដកហូតងារនេះទៅវិញដោយ លោកប្រធានាធិបតី ឌុណល ត្រម នៅថ្ងៃទី ៩ឧសភា ដោយបុព្វហេតុច្រើនដូចជា -មានបញ្ជាឱ្យស៊ើបអង្កេតរឿងការលួចជ្រៀតប្រព័ន្ធអាំងទ័រ ណែត ដើម្បីបំភ្លៃការបោះឆ្នោតក្នុងប្រទេសឱ្យបានរហូតដល់ចុងបញ្ចប់រឿងនេះ ត្រមគ្មានជំនឿថា ខូមីនឹងបញ្ចប់រឿងនេះឱ្យបានឆាប់ទេ -ការស៊ើបអង្កេតលើរឿងប្រើប្រាស់អ៊ីមែលផ្ទាល់ខ្លួនរបស់ ហ៊ីឡារី គ្លីងតុន ក្នុងកាងាររបស់



លោក ជេម ខូមី

ប្រទេសត្រមថា ខូមី ធ្វើមិនបានជោគជ័យទេ -បញ្ជាឱ្យបញ្ចប់ការស៊ើបអង្កេតលើលោក ម៉ារកិលហ្វ្លីន ដែលបានលាលែងពីតួរនាទីនាយកសន្តិសុខជាតិដែលត្រមយល់ថា ខូមីមិនត្រឹមតែមិនបានបញ្ចប់ទេ ហើយថែមទាំងស៊ើបអង្កេតចំពោះរូបលោកជាប្រធានាធិបតីថែមទៀត... ទាំងនេះជាបុព្វហេតុដែលនាំឱ្យមានការដកដំណែងលោក ជេម ខូមី។

រឿងនេះមិនបានចប់ត្រឹមនេះទេ បន្ទាប់ពីបណ្តេញចេញពីដំណែងប្រធានគណកម្មការសភាខាងការស៊ើបអង្កេតបានអញ្ជើញ ជេម ខូមី ឱ្យមកឆ្លើយសំនួរគណកម្មការសភា ដើម្បីស្វែងរកកំហុសប្រធានាធិបតីក្នុងការដែលប្រធានាធិបតីអាចនឹងប្រើអំណាចធ្វើឱ្យមានការរាំងស្ទះដំណើរការនៃក្រសួងយុត្តិធម៌,ការសួរដេញដោយចំពោះ ខូមី ក៏អាចនឹងបណ្តាលឱ្យមានជម្រុញឱ្យមានស្វែងរកដកដំណែងប្រធានាធិបតី ប្រសិនបើក្នុងចម្លើយថាមានប្រការណាមួយដែលប្រធានាធិបតីបានរំលោភលើរដ្ឋធម្មនុញ្ញនៃសហរដ្ឋអាមេរិក។

ក្នុងខណៈនេះលោកប្រធានាធិបតី ត្រម បានប្រើមេធាវីរបស់លោកឱ្យប្តឹង ខូមី ពីការដែល ខូមី និយាយមួលបង្កាច់ពីរូបលោក តែប្រជាពលរដ្ឋគេហាក់ដូចជាជឿថា អ្វីដែល ខូមី បាននិយាយក្នុងចម្លើយជូនព័ត៌មានទៅគណកម្មការសភាថាជាពាក្យពិតជាងពាក្យរបស់ការចោទប្រកាន់របស់ ឌុណល ត្រម ៕




# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

**AccuCare**
Home Care Agency
Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។




ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :

- រស់នៅផ្ទះរដ្ឋ

អាយុ ២២ ឆ្នាំឡើងទៅ

- មាសហែលស្តង់ដា

**ផលប្រយោជន៏ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីឃើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក ២៤ម៉ោង

**To be eligibled for GAFC you must:**

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# បក្សធំៗអះអាងឈ្នះរៀងៗខ្លួន

**ដោយ Ben Paviour, វណ្ណ រឿន និង Brendan O'Byrne**

***បក្សកាន់អំណាចបាត់បង់ឃុំ-សង្កាត់រាប់រយ ពេលមានអ្នកបោះឆ្នោតច្រើនជាប្រវត្តិសាស្ត្រ***

កាលពីម្សិលមិញ ទោះបីជាមិនទាន់មានលទ្ធផលផ្លូវការក្តី ក៏គណបក្សនយោបាយធំៗទាំងពីរបានអះអាងពីជ័យជម្នះរៀងៗខ្លួននៅក្នុងការបោះឆ្នោតឃុំ សង្កាត់ដែលប្រឈមហានិភ័យបំផុត និងមានអ្នកទៅបោះឆ្នោតច្រើនបំផុតនៅកម្ពុជា ដោយគណបក្សប្រជាជនកម្ពុជាលើកឡើងថា ខ្លួនឈ្នះអាសនៈមេឃុំ ចៅសង្កាត់ច្រើនជាង ហើយគណបក្សសង្គ្រោះជាតិអួតថា ខ្លួនឈ្នះយ៉ាងច្រើននៅក្នុងការបោះឆ្នោតដែលបណ្តាអ្នកសង្កេតការណ៍និយាយថា ភាគច្រើនគ្មានភាពខុសប្រក្រតីដូចការបោះឆ្នោតមុនៗ។

លទ្ធផលក្រៅផ្លូវការបង្ហោះដោយគេហទំព័រ Fresh News ដែលគាំទ្ររដ្ឋាភិបាលបានបង្ហាញថា គណបក្សប្រជាជនកម្ពុជាឈ្នះអាសនៈមេឃុំ ចៅសង្កាត់ចំនួន១.១៦៣អាសនៈ ធៀបនឹង៤៨២អាសនៈសម្រាប់គណបក្សសង្គ្រោះជាតិ និង១អាសនៈសម្រាប់គណបក្សខ្មែររួបរួមជាតិ។ តួលេខទាំងនោះបង្ហាញពីសន្ទុះកើនឡើងខ្លាំងសម្រាប់គណបក្សប្រឆាំង។ គណបក្សពីរផ្សេងគ្នា គឺគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សឈ្នះសរុបបានតែ៤០អាសនៈប៉ុណ្ណោះ កាលពីឆ្នាំ២០១២ មុនពេលច្របាច់បញ្ចូលគ្នាតាមក្រោយក្នុងឆ្នាំនោះ។

ប៉ុន្តែលោកស្រី មូរ សុខហួរ អនុប្រធានគណបក្សសង្គ្រោះជាតិមានមន្ទិលចំពោះតួលេខសរុបទាំងនោះ ដោយគូសបញ្ជាក់ថា គណបក្សប្រឆាំងមានលទ្ធផលបឋមផ្ទាល់ខ្លួនដែលខុសគ្នាពីលទ្ធផលបឋមផ្តល់ដោយគេហទំព័រ Fresh News។

លោកស្រីមានប្រសាសន៍កាលពីម្សិលមិញថា "បើកម្រិតកំហុសឆ្គងមានប្រហែល១ភាគរយនៃសន្លឹកឆ្នោតយើងត្រូវតែសុំឱ្យរាប់សន្លឹកឆ្នោតឡើងវិញ"ហើយថាសេចក្តីលម្អិតបន្ថែមទៀតសម្រាប់ផែនការរបស់គណបក្សប្រឆាំងនឹងចេញនៅថ្ងៃនេះ។

លទ្ធផលទាំងអស់មិនទាន់មានការបញ្ជាក់នៅឡើយទេ ខណៈទូរទស្សន៍ជាតិ ទទក ផ្សាយយឺតយ៉ាវនូវលទ្ធផលបឋមពីឃុំសង្កាត់មួយទៅឃុំសង្កាត់មួយដែលទទួលបានពីគណៈកម្មការធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) រហូតដល់យប់ជ្រៅ។

ទោះបីជា គ.ជ.ប គ្រោងចាប់ផ្តើមប្រកាសលទ្ធផលភ្លាមៗបន្ទាប់ពីការបោះឆ្នោតបិទបញ្ចប់ក្តី ក៏ស្ថាប័ននេះបានចំណាយពេលរាប់ម៉ោងទម្រាំចាប់ផ្តើមបង្ហោះលទ្ធផលបឋម ដោយលោក ហង្ស ពុទ្ធា អ្នកនាំពាក្យ គ.ជ.ប បានបន្ទោសការពន្យារពេលនេះទៅលើអ៊ីនធឺណិតគ្មានខ្សែដែលមានបញ្ហា។

តាមរយៈសារបង្ហោះតាមហ្វេសប៊ុកកាលពីយប់មិញ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងអំណរគុណគណបក្សនយោបាយ អ្នកបោះឆ្នោតអ្នកសង្កេតការណ៍ **តទៅទំព័រទី ១៥**



ការរាប់សន្លឹកឆ្នោតនៅវិទ្យាល័យមួយក្នុងរាជធានីភ្នំពេញ បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ កាលពីម្សិលមិញ។ រូបថត: ស៊ីវចាន់ណា,ឌឹខេមបូឌាដេលី

# RULING PARTY, OPPOSITION BOTH CLAIM COMMUNE ELECTION WIN

**by Ben Paviour, Van Roeun and Brendan O'Byrne | June 5, 2017**

A lack of official results did not stop both major political parties from claiming victory in Cambodia's highest-stakes and highest-turnout local elections to date on Sunday, with the CPP citing its dominance in winning commune chief seats and the CNRP boasting of huge opposition gains in a ballot monitors said was largely free of the irregularities that marred past votes.

Unofficial results posted by government-affiliated Fresh News showed the CPP winning 1,163 commune chief seats compared to 482 for the CNRP and one for the Khmer National Unity Party. Those numbers suggest big pickups for the opposition, whose composite parties-the Sam Rainsy Party and Human Rights Party-won just 40 seats in 2012 before merging later that year.

"If the margin of error is around 1 percent of votes, we need to ask for a recount," she said on Sunday, adding that more details for the opposition's plans would come today.

All results remained unconfirmed as of press time, as hosts on state-owned TVK slowly rattled off commune-by-commune results from the National Election Committee (NEC) late into the night.

Though the NEC was slated to start announcing results soon after polls closed at 3 p.m., it took hours for the body to begin posting results, with spokesman Hang Puthea blaming faulty wireless internet for the delay.

Prime Minister Hun Sen thanked political parties, voters, observers and authorities for a smooth, transparent, "free and fair" Election Day in a Facebook post last night, but did not mention results.

CPP spokesman SokEysan was more forthcoming.

"In boxing terms, CNRP cannot take away our belt," he said last night, adding that he could not confirm the Fresh News results but they were "probably similar" to the NEC's preliminary figures. "We definitely retained our belt."

"We lost a number of communes," he admitted. "We lost some battlefields, but we still won the war."

CNRP spokesman Yim Sovann said the fight had never been fair, citing a multi-year government crackdown that saw opposition members jailed and scattered abroad. There were also problems with Sunday's vote, he said, including disenfranchised garment workers and polling station violations.

Nonetheless, "this is a big success of the CNRP, which shows that CNRP will soon control 500 communes," he said. "In the 2018 national election, we will win at least 60 percent of the total vote."

Cham Bunthet, a political analyst and adviser **Continued to Page15**





ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ខណៈការបូកសរុបមានការយឺតយ៉ាវ CPP និង CNRP អះអាងពីជ័យជម្នះក្រោមហេតុផលផ្សេងៗគ្នា

**ដោយ Ben Paviour និង គុច ណារ៉េន | ថ្ងៃអង្គារ ទី៦ ខែមិថុនា ឆ្នាំ២០១៧**

ដោយការបូកសរុបលទ្ធផលផ្លូវការនៃការបោះឆ្នោតឃុំសង្កាត់កាលពីថ្ងៃ អាទិត្យ មានភាពយឺតយ៉ាវដោយសារបញ្ហាអ៊ីនធឺណិតនោះ គណបក្សនយោបាយធំៗទាំងពីរបានផ្តល់លទ្ធផលស្រដៀងគ្នា ប៉ុន្តែហេតុផលខុសគ្នាកាលពីម្សិលមិញលើបញ្ហាថា តើគណបក្សមួយណាជាអ្នកឈ្នះនៅក្នុងការបោះឆ្នោតដែលមានប្រជាពលរដ្ឋ៧លាននាក់បានចូលរួមជាតួលេខដែលច្រើនជាងសេចក្តីរាយការណ៍ដំបូងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ៣00.000នាក់ ។

លោក ហង្ស ពុទ្ធា អ្នកនាំពាក្យ គ.ជ.ប បាននិយាយថា ការពន្យារពេលចេញលទ្ធផល គឺមកពីអ៊ីនធឺណិតមានបញ្ហានៅតាមការិយាល័យខ្លះក្នុងចំណោមការិយាល័យបោះឆ្នោត២២.១៤៨កន្លែង ដោយលើកឡើងថា គ.ជ.បមិនអាចប្រកាសលទ្ធផលសម្រាប់ឃុំសង្កាត់ទាំងមូលបានទេ ប្រសិនបើមិនទទួលបាលលទ្ធផលដែលមានការបញ្ជាក់ពីការិយាល័យបោះឆ្នោតនីមួយៗនោះ ។

ខណៈលោក ហង្ស ពុទ្ធា បានលើកឡើងថា លោកសង្ឃឹមថា លទ្ធផលឆ្នោតនឹងបូកសរុបបញ្ចប់កាលពីម្សិលមិញនោះ គណបក្សធំៗទាំងពីរហាក់ដូចជាមានការសន្និដ្ឋានផ្ទាល់ខ្លួនរួចជាស្រេច ។

ផ្អែកលើទិន្នន័យប្រមូលដោយអ្នកអង្កេត-ការណ៍បោះឆ្នោតរបស់ខ្លួន គណបក្សសង្គ្រោះជាតិបានប៉ាន់ប្រមាណថា គណបក្សរបស់ខ្លួនឈ្នះតំណែងមេឃុំចៅសង្កាត់ចន្លោះពី៤៨២ដល់៤៨៦ក្នុងចំណោមតំណែងមេឃុំចៅសង្កាត់ចំនួន១.៦៤៦តំណែងដែលដាក់ឱ្យប្រកួតប្រជែងយក និងទទួលបាន៤៦ភាគរយ នៃសំឡេងឆ្នោតរបស់ប្រជាពលរដ្ឋបើធៀបនឹងគណបក្សប្រជាជនកម្ពុជាដែលទទួលបាន៥១ភាគរយ នេះបើយោងតាមព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្សសង្គ្រោះជាតិ ។

ដោយលើកឡើងពីការទទួលបានតំណែងមេឃុំចៅសង្កាត់ភាគច្រើនរបស់គណបក្សប្រឆាំងនៅក្នុងរាជធានីភ្នំពេញខេត្តសៀមរាប និងខេត្តកំពង់ចាមនោះ ព្រះអង្គម្ចាស់បានមានបន្ទូលកាលពីម្សិលមិញថា "វាជាជំហានដ៏សំខាន់ក្នុងការឆ្ពោះទៅរកជ័យជម្នះក្នុងការបោះឆ្នោតបន្ទាប់"។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបាននិយាយអំពីជ័យជម្នះស្រដៀងគ្នានេះកាលពីម្សិលមិញ ។

ឆ្លើយតបទៅនឹងអ្នករិះគន់ដែលលើកឡើងថា គណបក្សប្រជាជនកម្ពុជាចាញ់ឆ្នោតលោកនាយករដ្ឋមន្ត្រីបានបង្ហោះលទ្ធផលឆ្នោតគ្មានប្រភព និងមិនផ្លូវការលើហ្វេសប៊ុកកាលពីព្រឹកម្សិលមិញអមដោយរូបភាពស្តីពីលោកវាយកូនហ្គុលហ្វ៍ ។






ការរាប់សន្លឹកឆ្នោតនៅក្នុងការបោះឆ្នោតឃុំ សង្កាត់ ឆ្នាំ២០១៧ នៅថ្ងៃ អាទិត្យ ក្នុងរាជធានីភ្នំពេញ។ រូបថត: Hannah Hawkins/The Cambodia Daily

លោកបានសរសេរថា "សំឡេងឆ្នោតគណបក្សប្រជាជនមានការកើនឡើងប្រៀបនឹងការបោះឆ្នោតក្នុងឆ្នាំ២០១៣ និងខ្ពស់ជាងបក្សផ្សេងៗនៅកម្ពុជា"។

ដោយលើកឡើងអំពីចំនួនពលរដ្ឋចេញទៅបោះឆ្នោតសរុបដែលមិនទាន់ធ្វើបច្ចុប្បន្នភាពនោះ

**តទៅទំព័រទី ១៤**

# AS COUNT TICKS UPWARD, PARTIES SPIN COMPETING NARRATIVES

**by Ben Paviour and Kuch Naren | June 6, 2017**

With official tallies from Sunday's commune elections slowed by internet hiccups, both major political parties provided similar results but different stories on Monday on which had won a vote that drew a record 7 million Cambodians to the polls-300,000 more than had been previously reported by the National Election Committee (NEC).

NEC spokesman Hang Puthea attributed delays in releasing preliminary results to spotty internet at some of the 22,148 polling stations, saying it could not declare the results for an entire commune if it had not certified results from every station.

While Mr. Puthea said he hoped to have the results finalized on Monday, both major parties seemed to have already reached their own conclusions.

CNRP estimates, which are based on data gathered by its poll monitors, have the party winning between 482 and 486 commune chief seats out of the 1,646 spots up for grabs and 46 percent of the popular vote, compared to 51 percent for the CPP, said Prince SisowathThomico, who sits on the CNRP's steering committee.

"It's a very important step to winning the next election," he said on Monday, citing the opposition taking the majority of commune chief slots in Phnom Penh as well as Siem Reap and Kompong Cham provinces.

Prime Minister Hun Sen and CPP spokesman SokEysan told similar success stories on Monday.

Responding to critics who said the CPP lost the election, the polo-clad prime minister posted unsourced and unofficial election results on Facebook on Monday morning alongside photographs of a golf outing.

"The CPP's votes increased compared to the 2013 [national] election and it's also higher than other political parties," he wrote.

The ruling party won more than 51 percent of 6.7 million votes cast and added more than 300,000 votes to its 2013 election count, he wrote, citing outdated total turnout numbers that were updated in an NEC statement dated late Sunday night to more than 7 million.

The prime minister also claimed victory in the CNRP's failure to control the Senate, a largely symbolic body elected mostly by commune councilors whose president acts as head of state if the king becomes seriously ill.

Mr. Eysan gave similar figures to his boss as well as Prince Thomico on Bayon radio on Monday, saying his party had won 1,158 commune chief seats **Continued to Page 21**

ឌឺ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឺ ខេមបូឌា ដេលី

# ការធ្វើកូដកម្មរបស់កម្មករបង្ហាញពីកង្វល់ពាក់ព័ន្ធសហជីពនៅរោងចក្រ

**ដោយ ឆន ភារុណ និង** **hannahhawkins | ថ្ងៃសុក្រ ទី៩ខែមិថុនា ឆ្នាំ២០១៧**

កម្មករកាត់ដេរដែលនាំគ្នាធ្វើកូដកម្មយ៉ាងតិច១.000នាក់បានដាក់ញត្តិទៅកាន់ក្រសួងការងារកាលពីម្សិលមិញ?ដោយស្នើសុំឱ្យក្រសួងជួយធ្វើអន្តរាគមន៍នៅក្នុងការព្យួរការងារកម្មករចំនួន១១នាក់ ក្នុងនោះមាន១0នាក់អះអាងថា ពួកគេត្រូវបានរើសអើងដោយសារជាសកម្មជនរបស់សហជីពក្នុងស្រុក។

ក្នុងរឿងដាច់ដោយឡែកមួយទៀត ពួកគេក៏បានអះអាងផងដែរថា ពួកគេត្រូវបានបង្ខំឱ្យចូលរួមជាមួយសហជីពមួយគាំទ្រដោយរដ្ឋាភិបាលដែលបាន និងកំពុងកាត់ថ្លៃចូលជាសមាជិកពីប្រាក់ខែរបស់អ្នកដែលមិនមែនជាសមាជិកផ្លូវការនេះ បើយោងតាមការលើកឡើងរបស់កម្មករ និងសហជីពឯករាជ្យមួយ។

កម្មករមកពីរោងចក្រ សោតលេន (South land) ក្នុងខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញដំបូងឡើយបានធ្វើកូដកម្មនៅថ្ងៃសុក្រ ពាក់ព័ន្ធការទទួលបានថ្ងៃឈប់សម្រាកទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់កាលពីថ្ងៃអាទិត្យ ប៉ុន្តែបានបន្តធ្វើកូដកម្មទៀតនៅថ្ងៃពុធ ពេលមានព័ត៌មានការផ្ទុះឡើងថា មានការព្យួរការងារ។

លោក ប៉ាវ ស៊ីណា ប្រធានសហព័ន្ធសហជីពចលនាកម្មករ (CUMW) បានលើកឡើងថា កម្មករប្រហែល១.000នាក់បានចុះហត្ថលេខាលើញត្តិនេះទាមទារឱ្យក្រុមហ៊ុននេះ "ផ្តល់ការងារឱ្យសមាជិកសហជីពចំនួន១0នាក់វិញ រួមទាំងកម្មករម្នាក់ផង ហើយបញ្ឈប់ការរើសអើងកម្មករ និងការពារសិទ្ធិកម្មករ"។

ទោះជាយ៉ាងណា លោក ព្រាប មុន្នីសុវណ្ណ មន្ត្រីនៅសហព័ន្ធសហជីពចលនាកម្មករនេះបានប៉ាន់ប្រមាណថា មានកម្មករប្រហែល៨0ទៅ៩0ភាគរយនៃកម្មករចំនួន២.000នាក់នៅរោងចក្រសោតលេនបានចុះហត្ថលេខាលើញត្តិនេះ។

អ្នកបញ្ជាទិញសំខាន់ៗរបស់រោងចក្រសោតលេន មានក្រុមហ៊ុនសម្លៀកបំពាក់ Polo ក្រុមហ៊ុនសម្លៀកពាក់ Next Co និងក្រុមហ៊ុនសម្លៀកបំពាក់ American Eagle ដែលមិនអាចទាក់ទងសុំការធ្វើអត្ថាធិប្បាយបានកាលពីម្សិលមិញ។

លោក មុន្នីសុវណ្ណ បានលើកឡើងថា ការធ្វើកូដកម្មក្នុងសប្តាហ៍នេះបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា សហព័ន្ធសហជីពកម្ពុជា (CUF) ដែលអះអាងថា កម្មករភាគច្រើននៅរោងចក្រសោតលេន គឺជាសមាជិករបស់ខ្លួននោះមិននៅខាងកម្មករទេ ដោយឡើងពីអវត្តមានរបស់សហជីពនេះអំឡុងពេលកើតមានជម្លោះ។

លោកបានថ្លែងថា " CUF មើលទៅស្រដៀងជាម្ចាស់មួយផ្សេងទៀតនៅរោងចក្រនេះ។ ពួកគេមិនចង់ឱ្យកម្មករតវ៉ា ឬធ្វើការទាមទារឡើយ"។

លោក ប៉ាវ ស៊ីណា បានលើកឡើងទៀតថា កម្មករភាគច្រើនមិនដែលយល់ព្រមចូលរួមជាមួយសហព័ន្ធសហជីពកម្ពុជាទេ "ប៉ុន្តែសហជីពនេះ នៅតែបន្តកាត់ថ្លៃចូលជាសមាជិក"។ កាលពីខែមីនា ឆ្នាំ២០១៦ រោងចក្រ សោតលេន បានដាក់ពាក្យប្តឹងលោក ប៉ាវ ស៊ីណា ដោយចោទប្រកាន់លោកថា បានក្លែងឯកសារដោយសារសរសេរឈ្មោះ កម្មករពីរនាក់ខុសនៅក្នុងឯកសារដែលជូនដំណឹងមកក្រុមហ៊ុនថា កម្មករទាំងពីរនាក់នេះចង់បង្កើតសហជីពនៅទីនោះ។

ហួន ស្រស់ កម្មករម្នាក់ដែលបានចូលរួមជាមួយអ្នកតវ៉ាយ៉ាងច្រើននៅខាងក្រៅអគារក្រសួងការងារកាលពីម្សិលមិញ បានលើកឡើងថា ពេលគេទទួលនាងឱ្យចូលធ្វើការនៅរោងចក្រនេះកាលពីខែមករា គណៈគ្រប់គ្រងរោងចក្របានប្រាប់នាងឱ្យចូលរួមជាមួយសហព័ន្ធសហជីពកម្ពុជា។ ទោះជាយ៉ាងណានាងបានលើកឡើងថា នាងមិនសប្បាយចិត្តនឹងសេវានេះទេ។

នាងបាននិយាយថា "សហជីពនេះមិនដែលតំណាង ឬជួយយើងទេ ប៉ុន្តែពួកគេតែងតែត្រូវរ៉ូវគ្នាជាមួយរោងចក្រ"។ **តទៅទំព័រទី១៣**



កម្មកររោងចក្រកាត់ដេរប្រមូលផ្តុំគ្នានៅខាងក្រៅក្រសួងការងារក្នុងរាជធានីភ្នំពេញកាលពីម្សិលមិញ បន្ទាប់ពីដាក់ញត្តិសុំអន្តរាគមន៍ពីក្រសួងឱ្យជួយកម្មករ១0នាក់ដែលត្រូវបានព្យួរការងារឱ្យចូលធ្វើការវិញ។ Hannah Hawkins.ឌឺ ខេមបូឌា ដេលី

# WORKER STRIKE HIGHLIGHTS FACTORY UNION CONCERNS

**by Chhorn Phearun and Hannah Hawkins | June 9, 2017**

At least 1,000 striking garment workers submitted a petition to the Labor Ministry on Thursday seeking its intervention in the suspension of 11 workers, 10 of whom claim they were discriminated against for being activists of a local union.

Separately, they also claimed they were pressured into joining a government-backed union that has been deducting membership fees from the wages of those who are not official members, workers and an independent union said.

The workers from the Southland factory in Phnom Penh's PurSenchey district initially went on strike on Friday over obtaining leave to vote in Sunday's commune elections, but extended the strike on Wednesday when news broke of the suspensions.

Pav Sina, president of the Collective Union of Movement of Workers (CUMW), said about 1,000 workers signed the petition urging the company "to reinstate 10 unionists, including one worker, and to stop discrimination against workers and protect the workers' rights."

However, PreapMunysovann, an official at CUMW, estimated that about 80 to 90 percent of Southland's 2,000 workers signed the letter.

Southland's main international buyers are Polo, Next Co. and American Eagle, which could not be immediately reached for comment on Thursday.

Mr. Munysovann said this week's strike had made it clear that the union claiming membership of most of Southland's employees, the government-aligned Cambodian Union Federation (CUF), was not on the side of the workers, citing their absence during the dispute.

"CUF is similar to another kind of owner at the factory. They don't want workers to protest or make demands," he said.

Mr. Sina said most of the workers had never agreed to join CUF, "but the union keeps deducting their membership fees."

In March last year, Southland filed a complaint against Mr. Sina, accusing him of forgery when he misspelled two workers' names on a document informing the company that the pair intended to form a union there.

HounSras, a worker who had joined the throngs of protesters outside the Labor Ministry building yesterday, said that when she was hired by Southland in January, she was told by management to join CUF. However, she said she has been unhappy with the service.

"The union never represents or helps us, but they always get along with the factory," she said.

Worker Chou Ny said CUF "has never been with us to help," while Chhorn Phoen lamented that the $0.50 monthly membership fee deduction had not followed a signed membership contract.

"I have been waiting to leave the union," Mr. Phoen said. "If I leave the union right now, they might accuse me of colluding with the strikers. When everything calms down a bit, I will go to the union to withdraw."

CUF President Chuon Mom Thol, who also works as an adviser to the Labor Ministry, could not be reached yesterday. A woman who answered a general number listed for CUF online identified herself as Mr. Mom Thol's wife and said the union leader was currently in Switzerland.

Ken Loo, secretary-general of the Garment Manufacturers Association in Cambodia, of which Southland is a member, said on Wednesday that preventing workers from forming or joining unions was illegal, as was the deduction of union membership fees from workers' paychecks without proper authorization.

"I don't see how any factory can prevent the workers from organizing. That would be a violation of the law," he said, adding that the workers should file a complaint with the Labor Ministry. "They will do an investigation."

Mr. Loo said factories could only make deductions for union fees after they have been "explicitly authorized by the workers."

**Continued to Page13**

ឌី ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌី ខេមបូឌា ដេលី

តមកទំព័រទី ១២

## ការធ្វើកូដកម្មរបស់កម្មករបង្ហាញពី...

កម្មករម្នាក់ទៀតឈ្មោះ ជូ នី បានលើកឡើងថា សហព័ន្ធសហជីពកម្ពុជា "មិនដែលនៅជួយពួកយើងទេ" ខណៈកម្មករម្នាក់ទៀតឈ្មោះ ឆន ភ័ណ្ឌ បានសំដែងការសោកស្តាយថា ការកាត់ថ្លៃចូលជាសមាជិក៥០សេន មិនបានធ្វើតាមកិច្ចសន្យាចូលជាសមាជិកដែលមានចុះហត្ថលេខាឡើយ ។

ឆន ភ័ណ្ឌ និយាយថា "ខ្ញុំកំពុងរង់ចាំឱកាសចេញពីសហជីពនេះ" ។ កម្មកររូបនេះបាននិយាយបន្តថា "ប្រសិនបើខ្ញុំចេញពីសហជីពនេះក្នុងពេលនេះ គេប្រហែលជាចោទខ្ញុំថា ឃុបឃិតជាមួយអ្នកធ្វើកូដកម្ម ។ ពេលអ្វីៗស្ងប់ទៅវិញបន្តិច ខ្ញុំនឹងទៅសហជីពសុំដកខ្លួនវិញ" ។

លោក ជួន មុំថុល ប្រធានសហព័ន្ធសហជីពកម្ពុជាដែលក៏ធ្វើការជាទីព្រឹក្សាក្រសួងការងារដែរនោះមិនអាចទាក់ទងបានទេកាលពីម្សិលមិញ ។ ស្រ្តីម្នាក់ដែលលើកទូរស័ព្ទពេលគេហៅចូលលេខទូទៅនៅលើអ៊ីនធឺណិត សម្រាប់ទាក់ទងសហព័ន្ធសហជីពកម្ពុជានោះបានប្រាប់ថា គាត់គឺជាភរិយារបស់លោក ជួន មុំថុល ហើយបាននិយាយថា ប្រធានសហជីពរូបនេះកំពុងស្ថិតនៅក្នុងប្រទេសស្វីស ។

លោក កែន លូ អគ្គលេខាធិការសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ដែលមានរោងចក្រ សោតលេន ជាសមាជិកបានលើកឡើងកាលពីថ្ងៃពុធថា ការរារាំងកម្មករមិនឱ្យបង្កើតឬចូលរួមជាមួយសហជីពគឺជាទង្វើខុសច្បាប់ រីឯការកាត់ថ្លៃចូលជាសមាជិកពីប្រាក់ខែរបស់កម្មករដោយគ្មានការយល់ព្រមត្រឹមត្រូវក៏ខុសច្បាប់ដែរ ។

លោកបានមានប្រសាសន៍ថា "ខ្ញុំយល់ឃើញថា រោងចក្រមិនអាចរារាំងកម្មករមិនឱ្យបង្កើតសហជីពបានទេ នោះជាទង្វើរលោភបំពានច្បាប់" ។ លោកបានបន្តថា កម្មករគួរតែដាក់ពាក្យប្តឹងទៅក្រសួងការងារ ។ លោកបានបន្ថែមទៀតថា "គេនឹងធ្វើការស៊ើបអង្កេត" ។

អគ្គលេខាធិការរូបនេះបានលើកឡើងថា រោងចក្រអាចកាត់ថ្លៃចូលជាសមាជិកបាន លុះត្រាតែ "ទទួលបានការយល់ព្រមត្រឹមត្រូវពីកម្មករ" ជាមុនសិន ។

លោកបានថ្លែងថា "ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះជាធម្មតារោងចក្រមានការស្ទាក់ស្ទើរក្នុងការកាត់ថ្លៃចូលជាសមាជិកនេះ សូម្បីមានការយល់ព្រមក៏ដោយ" ។

ទោះបីជា វា "ខុសច្បាប់ទាំងស្រុង" សម្រាប់សហជីពក្នុងការកាត់ថ្លៃចូលជាសមាជិកដោយគ្មានការយល់ព្រមជាផ្លូវការក៏ដោយ តែវាជារឿងសាមញ្ញទៅហើយ នេះបើយោងតាមលោក មឿន តុលា នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) ។

លោកបានមានប្រសាសន៍ថា "វាកើតមាននៅកន្លែងការងារភាគច្រើន...កម្មករខ្លះអត់ដឹងថាសហជីពណាដែលខ្លួនមានទំនាក់ទំនង ឬបានចូលជាសមាជិកនោះទេ" ។ លោកបានបន្ថែមថា កម្មករភាគច្រើនមិនហ៊ាននិយាយនោះទេ ព្រោះខ្លាចគេបញ្ឈប់ពីការងារ ។

លោកបានថ្លែងបន្តថា "ពួកគាត់បានបញ្ជាក់ថា គេបានកាត់ប្រាក់ខែរបស់ពួកគាត់ ហើយពេលយើងសួរថា ហេតុអ្វីបានជាពួកគាត់មិនជូនដំណឹងដល់គណៈគ្រប់គ្រងឱ្យឈប់កាត់ថ្លៃចូលជាសមាជិក ពួកគាត់និយាយថា ពួកគាត់មិនហ៊ានធ្វើដូចច្នោះទេដោយសារពួកគាត់មានកិច្ចសន្យាធ្វើការងាររយៈពេលខ្លី" ។

លោក មឿន តុលា បានលើកឡើងទៀតថា បញ្ហានេះជាភ័ស្តុតាងបង្ហាញឱ្យឃើញពីកង្វះការអនុវត្តច្បាប់ដែលមិនត្រូវបានអនុវត្តឱ្យជាប់លាប់នៅក្នុងវិស័យកាត់ដេរនេះ ជាពិសេសក្នុងចំណោមសហជីព "លឿង" ដែលទទួលរងឥទ្ធិពលពីនិយោជក និងក្នុងចំណោមសហជីព "ក្រហម" ដែលជាសហជីពឯករាជ្យ ។ សហជីព "ក្រហម" មិនមានសម្ពន្ធភាពជាមួយរដ្ឋាភិបាលទេ ។

លោកបានលើកឡើងថា "វាមានការយល់ច្រឡំ និងស្មុគស្មាញខ្លាំងណាស់ថា តើសហជីពមួយណាជាសជីពលឿង និងមួយណាជាសហជីពក្រហម ។ សូម្បីតែសហជីពឯករាជ្យមួយចំនួនមិនចង់ទាំងនិយាយអំពីបញ្ហានេះផង" ។ លោកបានលើកឡើងទៀតថា វាមិនគ្រាន់តែពាក់ព័ន្ធនឹងការអប់រំអំពីសិទ្ធិទេ ព្រោះកម្មករខ្លះមិនជឿទុកចិត្តថា តទៅមុខទៀតនឹងទទួលបានលទ្ធផលឡើយ ។

លោកបានថ្លែងថា "ជួនកាលសហជីពលឿងធ្វើការយ៉ាងជិតស្និទ្ធជាមួយគណៈគ្រប់គ្រងហេតុដូច្នេះពេលកម្មករបដិសេធមិនចូលរួមជាមួយសជីពលឿងនេះកិច្ចសន្យាអាចត្រូវបានបញ្ចប់ ឬក៏មិនបន្តឱ្យទេ" ។

លោកបានបន្ថែមថា "មនុស្សភាគច្រើនមិនមានសេចក្តីក្លាហានគ្រប់គ្រាន់" ក្នុងការដាក់ពាក្យបណ្តឹងឡូយេ ។

លោកស្រី Esther Germans ដែលជាអ្នកគ្រប់គ្រងកម្មវិធីសម្រាប់រោងចក្រកាន់តែប្រសើរនៅកម្ពុជា (Better Factories Cambodia) ដែលបានវាយតម្លៃឱ្យរោងចក្រសោតលេនធ្លាក់ចំណាត់ថ្នាក់ក្នុងការវាយតម្លៃក្នុងឆ្នាំ២០១៣ពាក់ព័ន្ធបញ្ហាថា តើ "កម្មករមានសិទ្ធិសេរីភាពក្នុងការចូលរួមជាមួយសហជីព" ឬក៏អត់នោះ បានលើកឡើងថា អង្គការរបស់លោកស្រីបានទាក់ទងមកសហព័ន្ធសហជីពចលនាកម្មករ និងសហព័ន្ធសហជីពកម្ពុជាហើយដើម្បីសួរនាំអំពីជម្លោះនេះ ។

លោកស្រីបានលើកឡើងក្នុងអ៊ីម៉ែលមួយថា "យើងដឹងតាមរយៈការចុះតាមរោងចក្រជារៀងរាល់ថ្ងៃថា បញ្ហាជុំវិញសេរីភាពក្នុងការជួបជុំអាចមានភាពស្មុគស្មាញ និងមិនច្បាស់លាស់ ហើយថា ត្រូវមានការស៊ើបអង្កេតឱ្យបានល្អប្រសើរមុនពេលការទាញជាក់លាក់ណាមួយ" ។

លោកស្រីបានបន្ថែមថា "យើងប្រហែលជាពិនិត្យមើលបញ្ហានេះឱ្យបានកាន់តែស៊ីជម្រៅដោយសហការជាមួយសហជីព គណៈគ្រប់គ្រងរោងចក្រ និងក្រុមហ៊ុនសម្លៀកបំពាក់នានាអាស្រ័យលើថា តើករណីនេះនឹងលាតត្រដាងបែបណា" ។

ទាំងលោក ហេង សួគិ អ្នកនាំពាក្យក្រសួងការងារ និងអ្នកគ្រប់ទូទៅនៅរោងចក្រ សោតលេន ឈ្មោះ Mashiur Rah មាន សុទ្ធតែមិនឆ្លើយតបនឹងសំណើសុំការធ្វើអត្ថាធិប្បាយម្តងហើយម្តងទៀត ៕ **ស៊ុយឈាង**

Continued from page 12

## WORKER STRIKE HIGHLIGHTS...

"I would be quite surprised, because usually-even with the authorization-the factories are hesitant to make that deduction," he said.

Though it was "completely illegal" for unions to deduct membership fees without official approval, it is common, said Moeun Tola, executive director of labor rights organization Central.

"It happens in most of the workplaces…. Some workers don't know which union they are affiliated with or whether they are a member," he said, adding that many workers are afraid of speaking up for fear of termination.

"They confirm that their wage is deducted, and when we ask why they don't notify management to stop the deduction of membership fees, they say they are scared to do that, normally because they are on short contracts," he said.

Mr. Tola said the issue was evidence of a lack of law enforcement, which was applied inconsistently to the industry-particularly among "yellow" unions, which are "company-sponsored unions" or "unions influenced by the employer," and independent unions. "Red" unions are not affiliated with the government.

"It is very confusing and very complicated, which union is yellow, and which is red. Some international unions don't even want to talk about it," he said.

It was not just about education of rights, he said, as some workers did not trust that coming forward would yield results.

"Sometimes the yellow union works closely with the management, so when you refuse to join the yellow union, the contract could be terminated or not renewed," he said, adding that "most people are not brave enough" to file complaints.

Esther Germans, program manager for Better Factories Cambodia, which failed Southland in a 2013 assessment of whether "workers are free not to join



union," said that her organization had reached out to CUMW and Southland over the dispute.

"We know from visiting factories every day that issues around freedom of association can be complicated and unclear, and that a good investigation will need to take place before any definite conclusions can be drawn," she said in an email.

"Depending on how the case will unfold, we might take a closer look at the issue, in coordination with the union, factory management and brands," .

តមកទំព័រទី ១៥ ខណៈការបូកសរុបមានការយឺតយាវ...

លោកនាយករដ្ឋមន្ត្រីបានសរសេរបន្ថែមថា គណបក្សប្រជាជនកម្ពុជាឈ្នះជាង៥១ភាគរយ នៃសំឡេងឆ្នោតចំនួន ៦,៧ លានសំឡេង កើនឡើងជាង៣00.000សំឡេង ប្រៀបធៀបនឹងការបោះឆ្នោតឆ្នាំ២០១៣ ។

ចំនួនប្រជាពលរដ្ឋចេញទៅបោះឆ្នោតសរុបដែលត្រូវបានធ្វើបច្ចុប្បន្នភាពក្នុងសេចក្តីប្រកាសព័ត៌មានរបស់ គ.ជ.ប ចុះកាលបរិច្ឆេទនៅយប់ថ្ងៃអាទិត្យកើនឡើងដល់ជាង៧លាននាក់ ។

លោកនាយករដ្ឋមន្ត្រីក៏បានអះអាងផងដែរពីជ័យជម្នះលើគណបក្សសង្គ្រោះជាតិដែលបរាជ័យនៅក្នុងផែនការគ្រប់គ្រងព្រឹទ្ធសភាជាស្ថាប័ននិមិត្តរូបដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយក្រុមប្រឹក្សាឃុំសង្កាត់ភាគច្រើន និងជាស្ថាប័នដែលប្រធានរបស់ខ្លួននឹងដើរតួជាប្រមុខរដ្ឋស្តីទីពេលព្រះមហាក្សត្រអវត្តមាន ។

លោក សុខ ឥសាន បានផ្តល់តួលេខស្រដៀងគ្នានឹងលោកនាយករដ្ឋមន្ត្រី និងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ តាមវិទ្យុបាយ័ន កាលពីម្សិលមិញ ដោយលើកឡើងថា គណបក្សរបស់លោកទទួលបានតំណែងមេឃុំចៅសង្កាត់ចំនួន ១.១៥៨ ធៀបនឹងគណបក្សប្រឆាំងដែលទទួលបាន៤៨៧តំណែង។ លោកអះអាងថា តួលេខនេះ គឺគ្រប់គ្រាន់ឈ្នះឆ្នោតបានហើយ ។

លោក កឹម សុខា ប្រធានគណបក្សសង្គ្រោះជាតិដែលព្យាករអំឡុងយុទ្ធនាការឃោសនារយៈពេលពីរសប្តាហ៍ថា គណបក្សរបស់លោកនឹងឈ្នះ ៦0ភាគរយ នៃសំឡេងឆ្នោតរបស់ប្រជាពលរដ្ឋ នោះបានលើកឡើងពេលថ្លែងសុន្ទរកថា នៅទីស្នាក់ការកណ្តាលគណបក្សរបស់លោកក្នុងរាជធានីភ្នំពេញថា គណបក្សរបស់លោកឈ្នះ "ជិត ៥00ឃុំសង្កាត់" បើធៀបទៅនឹង ៤0 ឃុំ សង្កាត់ ដែលគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សឈ្នះរួមគ្នាក្នុងការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១២ ។ លោកបានមានប្រសាសន៍ថា ភាពប្រសើរឡើងនេះ"បញ្ជាក់ថា គណបក្សសង្គ្រោះជាតិទទួលបានជ័យជម្នះសម្រាប់ការបោះឆ្នោតបន្ទាប់" ។

អង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ (Situation Room) ដែលជាសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលនឹងបង្ហាញលទ្ធផលរបស់ខ្លួនដែលផ្អែកលើអ្នកសង្កេតការណ៍ឯករាជ្យនៅក្នុងសន្និសីទកាសែតមួយនៅព្រឹកនេះនេះបើយោងតាមការឱ្យដឹងពីអង្គការនេះ ។

ក្នុងចំណោមអ្នកបោះឆ្នោតដែលបានចុះឈ្មោះ ១0នាក់ មានជិត៩នាក់ បានបោះឆ្នោតកាលពីថ្ងៃអាទិត្យ នេះយោងតាមទិន្នន័យដែលបានធ្វើបច្ចុប្បន្នភាពរបស់គ.ជ.បស្តីពីចំនួនប្រជាពលរដ្ឋចេញមកបោះឆនោត ជាការកែប្រែទិន្នន័យដែលលោក សំ គន្ធាមី នាយកប្រតិបត្តិគណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា (និកហ្វិចញ) និយាយថា វាមកពីការចូលរួមរបស់ប្រជាពលរដ្ឋមិនមែនជាការលេងល្បិចទេ ។ លោកថ្លែងថា "ជាការពិតខ្ញុំសប្បាយចិត្តដែលបានឃើញប្រជាពលរដ្ឋចេញមកបោះឆ្នោតយ៉ាងច្រើន"។

លោក អ៊ូ វីរៈ នាយកអង្គការវេទិកាសាធារណៈបានមានប្រសាសន៍ថា លទ្ធផលប្រកៀកប្រកិតនៃការបោះឆ្នោតនេះមានប្រយោជន៍សម្រាប់អ្នកបោះឆ្នោត ព្រោះវានឹងជំរុញឱ្យគណបក្សនយោបាយធំៗផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតទៅលើសេចក្តីត្រូវការរបស់ពួកគាត់ ។ លោកគូសបញ្ជាក់ថា "ក្តីបារម្ភរបស់ខ្ញុំសម្រាប់បក្សប្រជាជន?គឺថាខ្លាចពួកគេយល់ខុសពីលទ្ធផលនៃការបោះឆ្នោតនេះ"។

លោកលើកឡើងទៀតថា បណ្តាញនៅមូលដ្ឋានដែលចាក់ឫសយ៉ាងជ្រៅ និងអត្ថប្រយោជន៍នៃការកំពុងកាន់តំណែងរបស់គណបក្សនេះបានធ្វើឱ្យខ្លួនមានប្រៀបខ្លាំងលើគណបក្សប្រឆាំងនៅក្នុងការបោះឆ្នោតឃុំសង្កាត់ដោយធ្វើឱ្យការអួតអាងរបស់គណបក្សនេះអំពីជ័យជម្នះភ្លូកទឹកភ្លូកដីរបស់ខ្លួនកាលពីម្សិលមិញហាក់ជាការសម្ញែងបូកពារនយោបាយ ឬពីភាពឆោតល្ងង់។

លោកធ្វើការកត់សម្គាល់ថា "ការពិតដែលពួកគេចាញ់ច្រើនបែបនេះ គួរតែជាសញ្ញាដាស់តឿន" ដោយព្យាករថា គណបក្សប្រជាជនកម្ពុជានឹង"លេងល្បែងនយោបាយបន្ថែមទៀត"តាមរយៈការបញ្ជូនសារជាក់លាក់ និងការបង្កើនសម្ពាធលើគណបក្សប្រឆាំង ។

លោកលើកឡើងបន្តថា ប៉ុន្តែគណបក្សសង្គ្រោះជាតិមិនបានទាញយកប្រយោជន៍ឱ្យអស់លទ្ធភាពពីលទ្ធផល"ដ៏អស្ចារ្យពិតប្រាកដ"របស់ខ្លួននៅថ្ងៃបោះឆ្នោតនោះទេដោយសារតែគណបក្សនេះរំពឹងទុកខ្ពស់ពេក។ គណបក្សនេះគួរតែចាត់ទុកការបោះឆ្នោតនេះថាជាការប្រកួតប្រជែងដ៏ប្រកៀកប្រកិត។

លោកមានប្រសាសន៍បន្ថែមទៀតថា ការបោះឆ្នោតកាលពីថ្ងៃអាទិត្យកន្លងទៅនេះ "គួរតែត្រូវបានចាត់ទុកជាជ័យជម្នះធំធេងសម្រាប់គណបក្សប្រឆាំងដោយសារគ្រប់បញ្ហាប្រឈមដែលពួកគេត្រូវជម្នះ"។

ព្រះអង្គម្ចាស់ ធម្មិកោ បានការពារការព្យាកររបស់លោក កឹម សុខា ដោយអះអាងថា គណបក្សមានអ្នកគាំទ្រច្រើនជាងមុន។ ព្រះអង្គបានចាត់ទុកការបោះឆ្នោតនេះថា "ឈ្នះ ឈ្នះ" ដោយសារគណបក្សសង្គ្រោះជាតិកើនឡើង សំឡេងគាំទ្រ ហើយគណបក្សប្រជាជនកម្ពុជានៅតែមានអាសនៈឃុំ សង្កាត់ និងសំឡេងឆ្នោតនាំមុខ ។

សំដៅដល់ការគំរាមកំហែងពីសំណាក់លោក ហ៊ុន សែន និងថ្នាក់ដឹកនាំផ្សេងទៀតរបស់គណបក្សប្រជាជនកម្ពុជាថាជ័យជម្នះរបស់គណបក្សប្រឆាំងនឹងបង្កឱ្យមានអំពើហិង្សាព្រះអង្គមានបន្ទូលថា "ខ្ញុំគិតថា វាគ្រប់គ្រាន់អាចធានាបានជាថ្មីចំពោះប្រជារាស្ត្រនៅកម្ពុជាថា នឹងគ្មានសង្គ្រាមទេពីព្រោះបើអ្នកគ្រប់គ្នាឈ្នះនឹងគ្មានសង្គ្រាមទេ" ៕

ស៊ុយឈាង និងសុខុម (រាយការណ៍បន្ថែមដោយ បែន សុខហ៊ាន)



តមកទំព័រទី ១០

# បក្សធំៗអះអាង ឈ្នះរៀងៗខ្លួន

និងសមត្ថកិច្ចសម្រាប់ការបោះឆ្នោតដោយរលូនមានតម្លាភាព "សេរី និងយុត្តិធម៌" ប៉ុន្តែលោកមិនបានលើកឡើងពីលទ្ធផលទេ។

លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានលើកឡើងកាលពីយប់មិញថា "នៅក្នុងភាសាប្រដាល់ គណបក្សសង្គ្រោះជាតិដណ្តើមខ្សែក្រវាត់របស់យើងមិនបានទេ"។ លោកបានបន្ថែមថា លោកមិនអាចបញ្ជាក់ពីលទ្ធផលរបស់គេហទំព័ Fresh News បានទេ ប៉ុន្តែវា "ប្រហែលជាស្រដៀងគ្នា" នឹងតួលេខបឋមរបស់ គ.ជ.ប. "យើងរក្សាបាននូវខ្សែក្រវាត់របស់យើង"។

លោកបានទទួលស្គាល់ថា "យើងបានចាញ់ឃុំ សង្កាត់មួយចំនួន។ យើងចាញ់សមរភូមិមួយចំនួន ប៉ុន្តែយើងនៅតែឈ្នះសង្គ្រាម"។

លោក យឹម សុវណ្ណ អ្នកនាំពាក្យគណបក្សសង្គ្រោះជាតិមានប្រសាសន៏ថា សមរភូមិនេះមិនដែលយុត្តិធម៌ទេដោយលើកឡើងពីការបង្ក្រាបជាច្រើនឆ្នាំពីសំណាក់រដ្ឋាភិបាលដែលធ្វើឱ្យសមាជិកគណបក្សសង្គ្រោះជាតិជាប់ពន្ធនាគារនិងខ្លះរត់ភៀសខ្លួនទៅបរទេស។ លោកថ្លែងថា ការបោះឆ្នោតកាលពីម្សិលមិញក៏មានបញ្ហាដែរ ក្នុងនោះរួមមានទាំងកម្មករកម្មការិនីបាត់បង់សិទ្ធិបោះឆ្នោត និងការរំលោភបំពាននៅតាមការិយាល័យបោះឆ្នោតផងដែរ។

ទោះជាយ៉ាងណាលោកគូសបញ្ជាក់ថា "នេះជាជោគជ័យដ៏ធំរបស់គណបក្សសង្គ្រោះជាតិដែលបង្ហាញថា គណបក្សសង្គ្រោះជាតិនឹងគ្រប់គ្រងឃុំសង្កាត់ចំនួន៥០០ឆាប់ៗនេះ។ នៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៨ យើងនឹងឈ្នះយ៉ាងតិច៦០ភាគរយនៃសំឡេងឆ្នោតសរុប"។

លោក ឆាំ ប៊ុនថេត អ្នកវិភាគនយោបាយ និងជាទីប្រឹក្សាគណបក្សប្រជាធិបតេយ្យមូលដ្ឋានដ៏ក្មេងខ្ចីមានប្រសាសន៏ថា គណបក្សទាំងពីរមានចំណុចត្រូវរៀងៗខ្លួន ប៉ុន្តែលោកបានជំរុញឱ្យមានការប្រុងប្រយ័ត្នចំពោះការទទួលស្គាល់លទ្ធផលប្រកាសដោយគេហទំព័រ Fresh News។

លោកមានប្រសាសន៏ទៀតថា សម្ទុះកើនឡើងសន្ធុះខ្លាំងនូវអាសនៈមេឃុំចៅសង្កាត់របស់គណបក្សសង្គ្រោះជាតិ "គឺជារឿងដ៏ល្អសម្រាប់គណបក្សប្រឆាំង។ វាអាចបង្កើតការជំរុញលើកទឹកចិត្តដ៏រឹងមាំចេញពីលទ្ធផលបែបនេះ"។

ក្នុងពេលជាមួយគ្នានេះ"វាជាសញ្ញាល្អសម្រាប់គណបក្សកាន់អំណាចដែលពួកគេអាចទប់ការគាំទ្របែបនេះបាន"បើទោះបីជាមានអ្នកទៅបោះឆ្នោតយ៉ាងច្រើនចេញទៅបោះឆ្នោតគាំទ្រគណបក្សសង្គ្រោះជាតិជាប្រវត្តិសាស្ត្រក្តី។ ហើយខណៈលោក សម រង្ស៊ី អតីតប្រធានគណបក្សសង្គ្រោះជាតិនិរទេសខ្លួននៅបរទេស ពេលនេះគណបក្សប្រឆាំងដែលដឹកនាំដោយលោក កឹម សុខា ហាក់មិនសូវមានសាមគ្គីគ្នាដូចកាលពីឆ្នាំ២០១៣ឡើយ។

លោកលើកឡើងថា ជ័យជម្នះ "អាចនឹងត្រូវគេដណ្តើមយកទៅវិញយ៉ាងងាយ នៅពេលយើងមិនសហការគ្នាមិនមានទស្សនវិស័យដូចគ្នា និងបេសកកម្មតែមួយ"។

លោក អ៊ា សុផល ដែលជាអ្នកនិពន្ធសៀវភៅមានចំណងជើងថា "ការពឹងផ្អែកជំនួយនៅកម្ពុជា: របៀបដែលជំនួយបរទេសធ្វើឱ្យប៉ះពាល់លទ្ធិប្រជាធិបតេយ្យបានលើកឡើងតាមរយៈសារអេឡិចត្រូនិកថា "វាជាជ័យជម្នះដ៏ធំបើនិយាយពីការកើនឡើង។ ខ្ញុំគិតថា កម្លាំងរបស់គណបក្សប្រជាជនកម្ពុជាបានថមថយយ៉ាងខ្លាំងនៅថ្នាក់ឃុំសង្កាត់។ ប្រសិនបើគណបក្សប្រជាជនកម្ពុជានៅតែមិនភ្ញាក់រលឹកថា យុទ្ធសាស្ត្របំភិតបំភ័យប្រជាពលរដ្ឋឱ្យគាំទ្រខ្លួនបានត្រឹមតែទទួលបានលទ្ធផលផ្ទុយទេនោះ ខ្ញុំមិនដឹងថា មានអ្វីផ្សេងអាចធ្វើឱ្យគណបក្សនេះភ្ញាក់រលឹកទេ។ មេរៀនគឺថា ធ្វើរឿងវិជ្ជមានឱ្យបានច្រើនជាងមុនរឿងអវិជ្ជមានឱ្យបានតិចជាងមុន"។

ការបោះឆ្នោតកាលពីម្សិលមិញល្អជាងឆ្នាំ២០១៣ ដោយមានអ្នកចូលរួមច្រើនបំផុតនៅក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា ដោយតួលេខរបស់ គ.ជ.ប បង្ហាញថា អ្នកបោះឆ្នោតមានចំនួនសរុប ៦.៧៤៣.៣២៩នាក់ ហើយគ្មានខេត្តណាមួយមានអ្នកទៅចូលរួមបោះឆ្នោតតិចជាង៨០ភាគរយឡើយ។ ចំនួននេះច្រើនជាងការបោះឆ្នោតលើកចុងក្រោយប្រមាណ៧.០០០នាក់ ហើយការបោះឆ្នោតកាលពីឆ្នាំ២០១២អ្នកមានបោះឆ្នោតជាង ១,៧ភាគរយ។

តទៅទំព័រទី ១៦



ការរាប់សន្លឹកឆ្នោតនៅខណ្ឌចំការមន ក្នុងរាជធានីភ្នំពេញ បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ កាលពីម្សិលមិញ។ រូបថត:ស៊ីវចាន់ណា,ឌឺខេមបូឌាដេលី

Continued from page 10

# RULING PARTY, OPPOSITION...

for the fledgling Grassroots Democracy Party, said that both parties had a point, though he urged caution at taking Fresh News results at face value.

The CNRP's big pickup in commune chiefs was "a very good take for the opposition party," he said. "They can build a very strong momentum off of this kind of result."

At the same time, "it's a good sign for the ruling party that they could maintain this kind of support" even with high voter turnout, which has historically favored the CNRP. And with former party President Sam Rainsy stuck abroad, the opposition, now led by KemSokha, appeared less unified than it had in 2013.

The victory "can be taken away easy when you're not working together, having the same vision, sending the same mission," he said.

Sophal Ear, author of "Aid Dependence in Cambodia: How Foreign Assistance Undermines Democracy," was less equivocal.

Polling station workers begin to count votes in Phnom Penh's Chamkar Mon district on Sunday. (Siv Channa /The Cambodia Daily)

"It's a smashing victory in terms of increase," he wrote in an email. "I think CPP strength is very seriously diminished at the commune level; if this is not a wake-up call that fear tactics have had the opposite effect of making people love the CPP even more, then I don't know what will."

"The message ought to be: less stick, more carrot," he added.

Sunday's election edged out 2013 as the country's most participatory election in Cambodian history, with the NEC tallying 6,743,329 voters and no province reporting less than an 80 percent turnout. That tops the last election by around 7,000 votes, and the 2012 ballot by over 1.7 million votes.

Early reports also suggested it was among the most peaceful and credible elections to date.

The NEC logged just one Election Day complaint as of on Sunday evening, according to Mr. Puthea.

NEC chairman SikBunhok praised the two-week campaign period in spite of threats by Mr. Hun Sen and other senior CPP officials that any CNRP victory could cause war, chaos and death.

"The general evaluation found that the political parties conducted the election campaign within a politically mature manner, compromising each other more and obeying the principles of law, regulations and procedures of the election campaign," he said at a news conference.

A statement released by a coalition of civil society groups that dubbed themselves "The Situation Room" said the election had largely gone "smoothly, safely and peacefully," a view that was echoed by Transparency International Cambodia in its own initial news statement.

Local and international election observers cited a handful of incidents, including reports currently under investigation by the Committee for Free and Fair Elections in Cambodia (Comfrel) of an influx of hundreds of soldiers voting in a handful of communes as well as a report in Kandal province of threats against election observers in two communes.

Among the first to vote was Mr. Hun Sen, who blessed his ballot with a kiss to the box where he cast it at a teacher training center near his sprawling estate in Kandal province's Takhmao City.

"This ink looks like it can't be erased," he told reporters after voting, holding his finger aloft.

The NEC admitted it purchased the ink from an Indian supplier even after its tests of samples showed it could be removed using a hair care product, sparking concerns among election watchdogs and the CNRP.

The prime minister then rebuked a foreign reporter with The Phnom Penh Post after the journalist asked Mr. Hun Sen which **Continued to Page19**

តមកពីទំព័រទី ១៩

## បក្សធំៗអះអាង ឈ្នះរៀងៗខ្លួន

របាយការណ៍បឋមក៏បានលើកឡើងដែរថា វាស្ថិតក្នុងចំណោមការបោះឆ្នោតដែលសន្តិភាពបំផុត និងគួរឱ្យជឿទុកចិត្តបំផុត។

យោងតាមលោក ហង្ស ពុទ្ធា បានឱ្យដឹងថា គ.ជ.ប ទទួលបានពាក្យបណ្ដឹងតែមួយប៉ុណ្ណោះ គិតមកទល់ល្ងាចម្សិលមិញ។

លោក សុិក ប៊ុនហុក ប្រធាន គ.ជ.ប បានលើកសរសើរដល់ការធ្វើយុទ្ធនាការឃោសនាបោះឆ្នោតរយៈពេល២សប្ដាហ៍ ទោះបីជាមានការគំរាមពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជាផ្សេងៗទៀតថា ជ័យជម្នះរបស់គណបក្សសង្គ្រោះជាតិអាចបង្កឱ្យកើតមានសង្គ្រាម ភាពចលាចល និងការបាត់បង់ជីវិតក៏ដោយ។

លោកបានមានប្រសាសន៍អំឡុងសន្និសីទកាសែតមួយថា "តាមការវាយតម្លៃជាទូទៅឃើញថា គណបក្សនយោបាយបានធ្វើសកម្មភាពឃោសនាប្រកបដោយភាពចាស់ទុំខាងនយោបាយ មានការយោគយល់អធ្យាស្រ័យគ្នាច្រើន រួមទាំងគោរពបាននូវគោលការណ៍ច្បាប់បទបញ្ជា និងនីតិវិធីសម្រាប់ការឃោសនាបោះឆ្នោត"។

សេចក្ដីថ្លែងការណ៍មួយចេញដោយអង្គការសម្ព័ន្ធសង្គមស៊ីវិលដែលហៅខ្លួនឯងថា "បន្ទប់ស្ថានការណ៍" (The Situation Room) បានលើកឡើងថា ការបោះឆ្នោតនេះភាគច្រើនមានដំណើរការ ដោយរលូន ប្រកបដោយសុវត្ថិភាព និងសន្តិវិធី" ជាទស្សនៈដែលត្រូវបានបន្ទរដោយអង្គការតម្លាភាពកម្ពុជានៅក្នុងសេចក្ដីប្រកាសព័ត៌មានដំបូងរបស់ខ្លួន។

ក្រុមអ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិបានលើកឡើងថា មានបញ្ហាមួយចំនួនកើតឡើង រួមមាន សេចក្ដីរាយការណ៍ដែលថា មានទាហានជាច្រើនរយនាក់បាននាំគ្នាមកបោះឆ្នោតនៅក្នុងឃុំមួយចំនួន និងដែលបច្ចុប្បន្នកំពុងស្ថិតក្រោមការស៊ើបអង្កេតដោយ គណៈកម្មាធិការ ដើម្បីការបោះឆ្នោត ដោយសេរីនិងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) ក៏ដូចជាសេចក្ដីរាយការណ៍នៅក្នុងខេត្តកណ្ដាលអំពីការគំរាមកំហែងលើអ្នកសង្កេតការណ៍បោះឆ្នោតនៅក្នុងឃុំចំនួនពីរ។

ក្នុងចំណោមអ្នកដែលទៅបោះឆ្នោតដំបូងគេគឺលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានថើបហិបឆ្នោតក្រោយដាក់សន្លឹកឆ្នោតចូលទៅក្នុងហិបនៅមណ្ឌលបោះឆ្នោតសាលាគរុកោសល្យ និងវិក្រឹតការ ខេត្តកណ្ដាល ដែលនៅមិនឆ្ងាយពីភូមិគ្រឹះដ៏ស្កឹមស្កៃរបស់លោកក្នុងក្រុងតាខ្មៅ ខេត្តកណ្ដាល។

លោកថ្លែងទៅកាន់អ្នកយកព័ត៌មានបន្ទាប់ពីបោះឆ្នោតរួចដោយលើកចង្អុលដៃបង្ហាញថា "ទឹកខ្មៅនេះមើលទៅលុបមិនជ្រះទេ"។

គ.ជ.បទទួលបានស្គាល់ថា ខ្លួនបានទិញទឹកខ្មៅពីក្រុមហ៊ុនផ្គត់ផ្គង់នៅឥណ្ឌា សូម្បីបន្ទាប់ពីការធ្វើតេស្តរបស់ខ្លួនលើទឹកថ្នាំគំរូបង្ហាញថា វាអាចលុបជ្រះដោយប្រើផលិតផលថែរក្សាសក់ក៏ដោយ ដោយធ្វើឱ្យកើតមានក្ដីព្រួយបារម្ភក្នុងចំណោមអ្នកឃ្លាំមើលការឆ្នោត និងគណបក្សសង្គ្រោះជាតិ។

បន្ទាប់មកលោកនាយករដ្ឋមន្ត្រី បានរិះគន់អ្នកយកព័ត៌មានម្នាក់មកពីភ្នំពេញ ក្រោយពេលអ្នកយកព័ត៌មានរូបនេះបានសួរលោក ហ៊ុន សែន ថាតើគណបក្សមួយណាដែលលោកបោះឆ្នោតឱ្យ។

ដោយប្រើពាក្យពេចន៍ដែលសំដៅដល់ពលរដ្ឋលោកខាងលិច លោកមានប្រសាសន៍ថា "មានភ្នែកសមកសួរថា បោះឱ្យគណបក្សណា"។

លោកមានប្រសាសន៍បន្ថែមថា "បរទេសបើមករបៀបបែបអ៊ីចឹង ដូចជាល្ងង់"។ លោកបានបន្ថែមទៀតថា វាជាសិទ្ធិរបស់ពលរដ្ឋគ្រប់រូបក្នុងការរក្សាភាពសម្ងាត់អំពីជម្រើសរបស់ខ្លួន។

ប៉ុន្មានម៉ោងក្រោយមកលោក កឹម សុខា ប្រធានគណបក្សសង្គ្រោះជាតិបានបោះឆ្នោតនៅសាលាបឋមសិក្សាមួយក្នុងខណ្ឌមានជ័យ រាជធានីភ្នំពេញ។

ក្រោយចុះធ្វើយុទ្ធនាការឃោសនារយៈពេលពីរសប្ដាហ៍ទូទាំងប្រទេសរួចភ្លាម លោក កឹម សុខា បានលើកឡើងថា លោកសង្ឃឹមថា គណបក្សរបស់លោកនឹង "ទទួលសំឡេងឆ្នោតជាង៦០ភាគរយ" ដោយទំនងជាលើកឡើងម្ដងទៀតពីការព្យាករនាពេលកន្លងមករបស់លោកដែលថា គណបក្សរបស់លោកនឹងទទួលបានសំឡេងឆ្នោតក្នុងចំនួនប៉ុណ្ណឹង។

មុនពេលទំនងជាផ្ដោតគោលដៅលើលោកនាយករដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជាផ្សេងៗទៀតដែលបានព្រមានអំពីអំពើហិង្សា ប្រសិនបើគណបក្សប្រឆាំងឡើងកាន់អំណាចនោះ លោក កឹម សុខា បានមានប្រសាសន៍ថា "ខ្ញុំដឹងថា កម្លាំងនៃការគាំទ្ររបស់យើងមានការកើនឡើងចាប់តាំងពីការបោះឆ្នោតចុងក្រោយម្ល៉េះ"។

លោកបានថ្លែងបន្ថែមថា "ខ្ញុំជឿជាក់ថា ប្រជាពលរដ្ឋមិនចង់ឱ្យមនុស្សអាក្រក់ដឹកនាំប្រទេសទេ"។

ទម្រាំតែលោក កឹម សុខា បានលើផ្លូវឆ្ពោះមករកការបោះឆ្នោតនេះ **តទៅទំព័រទី ១៧**



តមកទំព័រទី ១៧

# បក្សធំៗអះអាង ឈ្នះរឿងៗខ្លួន

លោកបានប្រឈមនឹងសំណុំរឿងផ្លូវច្បាប់បន្តបន្ទាប់កាលពីឆ្នាំមុន។

តំណាងរាស្ត្ររូបនេះតំណាងមណ្ឌលកំពង់ចាម ហើយធ្លាប់បោះឆ្នោតនៅទីនោះ ប៉ុន្តែដោយសារមានសំណុំរឿងតុលាការជាបន្តបន្ទាប់កាលពីឆ្នាំមុន វាបានធ្វើឱ្យលោករត់ទៅសម្ងំលាក់ខ្លួនក្នុងទីស្នាក់ការកណ្តាលរបស់គណបក្សសង្គ្រោះជាតិដើម្បីគេចពីការចាប់ខ្លួន។ លោក កឹម សុខា បានចេញពីទីស្នាក់ការកណ្តាលនេះក្នុងរយៈពេលខ្លី កាលពីខែតុលាដើម្បីទៅចុះឈ្មោះបោះឆ្នោត ហើយទទួលបានព្រះរាជទានលើកលែងទោសក្នុងខែធ្នូ សម្រាប់បទចោទប្រកាន់ដែលនាំឱ្យអាជ្ញាធរតាមចាប់ខ្លួនរូបលោក។

លោក កឹម សុខា និងលោក ហ៊ុន សែន ដែលបង្ហាញវត្តមានខុសពីសព្វមួយដងអំឡុងរដូវកាលធ្វើយុទ្ធនាការឃោសនាបោះឆ្នោតនោះ សុទ្ធតែប្រើពាក្យពេចន៍ប្រកបដោយសន្តិវិធីពេលបិទបញ្ចប់ការហែក្បួនឃោសនាសម្រាប់គណបក្សរបស់ខ្លួននៅក្នុងរាជធានីភ្នំពេញកាលពីថ្ងៃសុក្រដែលកៀរគរអ្នកគាំទ្របានរាប់ម៉ឺននាក់រៀងៗខ្លួន។ ថ្នាក់ដឹកនាំទាំងពីរបានងាកទៅរកប្រធានបទចាស់ដោយលោក កឹម សុខា បានជំរុញឱ្យមានការផ្លាស់ប្តូរ និងមានការធ្វើវិមជ្ឈការ រីឯលោកនាយករដ្ឋមន្ត្រីវិញបានព្រមានអំពីសង្គ្រាមប្រសិនបើគណបក្សប្រឆាំងមួយនេះឡើងកាន់អំណាច។

ទោះជាយ៉ាងណាអ្វីៗប្រព្រឹត្តទៅដោយមានភាពស្ងប់ស្ងាត់នៅសាលាបឋមសិក្សាកុលាប១កាលពីម្សិលមិញដែលមានការិយាល័យបោះឆ្នោត ៥កន្លែងសម្រាប់អ្នកបោះឆ្នោតនៅក្នុងសង្កាត់ស្រះចក ខណ្ឌដូនពេញ។

អ្នកបោះឆ្នោតប្រហែល៨០ភាគរយនៅការិយាល័យមួយក្នុងចំណោមការិយាល័យទាំងប្រាំបានបោះឆ្នោតរួចរាល់នៅត្រឹមម៉ោង១១ព្រឹកនេះ បើយោងតាមអ្នកអង្កេតការណ៍បោះឆ្នោតម្នាក់មកពីគណបក្សប្រជាជនកម្ពុជាឈ្មោះ ថាច់ គឹមហ៊ុន។ អ្នកស្រី ថាច់ គឹមហ៊ុន និងអ្នកអង្កេតការណ៍ផ្សេងទៀតមកពីគណបក្សសង្គ្រោះជាតិ ខុមប្រៀល និងសហព័ន្ធយុវជនកម្ពុជា បានលើកឡើងថា ការបោះឆ្នោតនៅមណ្ឌលនេះមានដំណើរការដោយរលូន ដោយអ្នកបោះឆ្នោតភាគច្រើនបានដឹងអំពីនីតិវិធីបោះឆ្នោត។

លោក អៀង សិរីពង្ស អាយុ៤៥ឆ្នាំ ជាមន្ត្រីនៅក្រសួងសុខាភិបាល ដែលមានឪពុកម្តាយមកជាមួយបានលើកឡើងថា លោកមើលឃើញថា មិនមានការប៉ុងប៉ងបង្ខិតបង្ខំដូចអំឡុងការបោះឆ្នោតមុនៗទេ។

លោកបាននិយាយថា "វាប្រសើរជាងមុន"។ លោកបានបន្តថា "ប្រជាពលរដ្ឋដឹងពីរបៀបបោះឆ្នោត"។

ការបោះឆ្នោតនេះក៏ជាបញ្ហាគ្រួសារផងដែរសម្រាប់អ្នកស្រី ពេជ្រ តែគីមភៀន អាយុ៤០ឆ្នាំ ដែលពាក់អាវផ្កាដូចនឹងម្តាយរបស់អ្នកស្រីដែរ។

អ្នកស្រីបាននិយាយថា "ខ្ញុំសប្បាយរីករាយណាស់ដល់ថ្នាក់ដេកមិនលក់កាលពីយប់មិញ"។ អ្នកស្រីបានលើកឡើងទៀតថា រីឯការបោះឆ្នោតវិញមានដំណើរការទៅដោយរលូន។ "ខ្ញុំអត់មានត្រូវរង់ចាំទាល់តែសោះ"។

ម្យ៉ាងវិញទៀត អ៊ុច ធារី បានលើកឡើងថា នាងចំណាយពេលកន្លះម៉ោងសម្រាប់ការបោះឆ្នោត។

លេខាអាយុ២២ឆ្នាំរូបនេះបាននិយាយថា "ខ្ញុំមានអារម្មណ៍រំភើប"។ នាងបាននិយាយបន្ថែមថា "ខ្ញុំបោះឆ្នោតឱ្យគណបក្សដែលខ្ញុំស្រឡាញ់"។

លោក ឆាំ ប៊ុនថេត បានព្យាករថា អារម្មណ៍បែបនេះប្រហែលជាលែងមានហើយនៅឆ្នាំក្រោយ ជាពេលដែលគណបក្សទាំងពីរសុទ្ធតែចង់បានជ័យជម្នះរៀងៗខ្លួននៅក្នុងការបោះឆ្នោតជាតិឆ្នាំ ២០១៨។

លោកបានមានប្រសាសន៍ថា "ខ្ញុំគិតថា នឹងមានការប្រឈមច្រើន និងសម្ពាធច្រើន សម្រាប់ការបោះឆ្នោតនៅឆ្នាំក្រោយនេះ"៕ **សុខុម និង ស៊ុយឈាង**

(រាយការណ៍បន្ថែមដោយ Hannah Hawkins គុច ណារ៉ែន សេក ឧត្តម ឆន ParuN Janelle ត្រែកាអ៊ូច សូនី និង Matt Surrusco)













**តពីលេខមុន**

ត្រឡប់មករកកន្លែងវិញ កុំឱ្យលោកគ្រូសង្ស័យសម្រាកបន្តិចក៏ដេកលក់ទាំង២នាក់ទៅ។

ភ្ញាក់ឡើងវិញ លោកគ្រូចៅអធិការដេញអាចៅទាំងគូរ ឱ្យទៅជួយបោសសំអាតទីធ្លាមុខសាលាបាលី ពីព្រោះខ្យល់បោកបក់ខ្លះៗនោះនាំសម្រាមនឹងស្លឹកឈើងាប់ឱ្យពេញមុខសាលានោះ ជាមួយគ្នានោះលោកគ្រូប្រមូលបាននេន៣-៤អង្គមកទៀត ក៏ចាត់ឱ្យសំអាតជុំវិញសាលាបាលីនោះទាំងមូលតែម្តង។ ម៉ោងជិត៤ការងារក៏ហើយស្រេច "អ័រដូណង់" លោកកុម៉ង់ដង់ម៉ាំង ឈ្មោះ "សាយ" មានឋានន្តរសក្តិជា "កាប៉ូរ៉ាល់ស្វែហ្វ"ក៏មកដល់តែម្តង ដើម្បីទទួលចៅពិនត្រឡប់ទៅបន្ទាយវិញ តែមកដោយថ្មើរជើង។ ថ្វាយបង្គំទូលលោកគ្រូរួចហើយលោកតាក៏មានសង្ឃដីការផ្តាំថា "បើលោកសាយឯងជាអ្នកនាំអាចៅពិនមកថ្ងៃស្អែកសុំនាំមកឱ្យបានព្រឹកបន្តិចអាត្មានឹងនាំគេចេញទៅតាមបិណ្ឌបាត្រ តើបានទេ?" ពូសាយតបវិញ ថា "ខ្ញុំកូណានៅ"រាស់សមប្លឺម៉ង់" ចប់ម៉ោង៧ព្រឹក ម៉ោង៧កន្លះយ៉ាងយូរខ្ញុំកូណានឹងនាំចៅពិន មកដល់វត្តវិញហើយ តេជគុណ!" លោកគ្រូក៏ឆ្លើយតបវិញថា "ល្អហើយ អាត្មាចេញទៅបិណ្ឌបាត្រនៅម៉ោង៨ណា" ពូសាយនឹង ចៅពិន ក៏ក្រាបថ្វាយបង្គំលាលោកគ្រូពេលនោះតែម្តង។

ចៅពិន សង្កេតឃើញថា ពូសាយមិនដើរទៅតាមផ្លូវឡានដូចពេលដែលខ្លួនជិះមកទេ ហើយនាំខ្លួនសំដៅចុះទឹកស្ទឹងតែម្តងចំជាពេលនោះទឹករាក់ មានចង្អូរតូចៗហូរលើដីខ្សាច់ពណ៌លឿង ហើយក្តៅគគុកនៅឡើយ នឹងដុំថ្មរដេបរដុបតែគេអាចដើរឆ្លងពីត្រើយម្ខាងទៅម្ខាងទៀតយ៉ាងងាយស្រួល ។ មានអ្នកងូតទឹករាវលាសគ្រំសើចក្អាកក្អាយ គេអាចមើលឃើញកូនត្រីតូចៗហែលច្រវ៉ាត់ ពូសាយរួសរាយណាស់ មាឌធំក្រអាញ ហៅចៅពិន ឱ្យជិះក៏ខ្លួន ដើម្បីឆ្លងទឹកធ្វើឱ្យចៅពិនរីករាយឥតឧបមា ពូសាយនាំនិយាយលេងសើចជាកូនក្មួយឱ្យកក្អឹក។ ទៅដល់ច្រាំងម្ខាងទៀត មានរោងចក្រមួយយ៉ាងធំមានម៉ាស៊ីនរោទ៍ឡើងគគ្រឹក គឺម៉ាស៊ីនភ្លើងក្រុងកំពង់ស្ពឺដែលផ្តើមដំណើរការពេញកម្លាំងតែពេលយប់ពីម៉ោង៦យប់ដល់ម៉ោង៦ព្រឹក ទើបបន្ថយកម្លាំងមកតិចវិញនៅពេលព្រឹកសម្រាប់តែមន្ទីរពេទ្យឬការិយាល័យរដ្ឋបាលសំខាន់ៗតែប៉ុណ្ណោះ។ គេ



មានសង់ទំនប់ទឹកមួយ កំពស់ប្រមាណ១ម៉ែត្រកាត់ស្ទឹង ត្រង់កន្លែងម៉ាស៊ីនភ្លើងនោះតែម្តងនោះគឺដើម្បីតម្លើងកំពស់ទឹកឱ្យបានខ្ពស់សម្រាប់គេបូមទឹកយកទៅធ្វើឱ្យម៉ាស៊ីនភ្លើងនោះចុះកំដៅឱ្យធ្វើការបានយូរ។ កំពង់ស្ពឺជាខេត្តរាំងស្ងួតតែគ្មាននរណានឹងឃើញទប់ទឹកស្ទឹងព្រែកត្នោតសម្រាប់យកទឹកស្រោចដំណាំទេ នៅផ្ទះចៅហ្វាយខេត្ត ឬបន្ទាយទាហ៊ាន ឬផ្ទះផ្សារប្រជុំជន គេធ្វើប៉មពីសីម៉ង់ខ្ពស់ៗ (សាតូដូ-Chateau d’eau ) សម្រាប់បូមទឹកបញ្ចូលប៉មនោះ ហើយបង្ហូរតាម "ទុយោ" ចែកចាយទឹកដល់ផ្ទះតែម្តង។ មកដល់បន្ទាយវិញ ពូសាយនាំចៅពិនទៅជួបរាយការដល់លោកកុម៉ង់ដង់ហើយទើបនាំចៅពិនទៅផ្ទះជូនលោកស្រី ចៅពិនរីករាយណាស់ដោយបានជួបម្តាយវិញ ហើយរាយការប្រាប់ម្តាយពីព្រឹត្តិការដែលបានកើតនៅវត្តជាពិសេសនៅតាមផ្លូវត្រឡប់មកផ្ទះវិញ។

ពេលបាយល្ងាចមកដល់ ពូរិនជា "អ័រដូណង់" ម្នាក់ទៀត នៅជួយធ្វើម្ហូបលោកស្រីរៀបម្ហូបដាក់តុបាយរួចហើយ អញ្ជើញគ្រួសារមកពិសារបាយគ្រួសារទាំងមូលជួបជុំគ្នាពិសារបាយយ៉ាងឆ្ងាញ់ លោកម៉ាំងងាកមកសួរចៅពិនថា "យ៉ាងម៉េចទៅកូន នៅវត្តថ្ងៃនេះ?" ចៅពិនតបថា "បាទ ប៉ា អត់មានអ្វីកើតឡើងទេ, ថ្ងៃស្អែកទើបលោកគ្រូឱ្យទៅតាមលោកបិណ្ឌបាត្រ" លោកស្រីចាំបន្តិចដោយឥតនរណាសួរបន្ត ក៏លើកឡើងថា "កូននៅវត្តញ៉ាំបាយបានច្រើនទេ?" ចៅពិនប្រញាប់តបថា "បាទម៉ាក់ បាយនឹងម្ហូបមានច្រើនណាស់ កូននឹងអាថា ញ៉ាំមិនអស់ទេ!" បងស្រីក៏ឆ្លៀតកំប្លែងឱ្យប្អូនថា "មានខ្ចប់ម្ហូបឆ្ងាញ់ទុកផ្ញើបងខ្លះទេ?" ប្អូនប្រុសក៏តបរឹងថា "អត់ផងអ្នកបង!" ទាំងអស់គ្នាសើចគឹលឡើង...រួចក៏បន្តពិសារបាយរហូតចប់ងើបពីតុទាំងអស់គ្នា,... ពូរិនក៏មកលើកចានសំអាតតុបាយ លានចានទុកដាក់រួច ទើបលាលោកស្រីត្រឡប់ទៅផ្ទះវិញនៅម៉ោង៨យប់ នៅពេលលោកកុម៉ង់ដង់កំពុងអង្គុយស្តាប់វិទ្យុនៅក្នុងសាឡុងលោក រីឯលោកស្រីត្រៀមចង្កៀងប្រេងកាតដាក់លើតុរួចជាស្រេចសម្រាប់ពេលត្រូវការវាពេលយប់ ចំណែកឯចង្កៀង "ម៉ាងសុង" ប្រើប្រេងកាតមានបញ្ចេះប្រើសំបុកមានពន្លឺខ្លាំង ទុកប្រើសម្រាប់ពេលមានមនុស្សច្រើននៅផ្ទះ ។

ម៉ោង៨កន្លះយប់លោក ម៉ាំង ផ្តើមចូលបន្ទប់ដំណេកលោកស្រីតែងនាំកូនទៅគក់ច្របាច់ជូនឪពុករបស់គេ លោក ម៉ាំង ចូលចិត្តឱ្យភរិយាខ្លួនចាត់ការរបៀបនេះណាស់ តែថ្ងៃខ្លះដោយកូនៗរវល់លោកស្រីគក់ច្របាច់តែម្នាក់ឯង ហើយក៏ជាវិធីដែលធ្វើឱ្យកូននឹងឪពុកបាននៅជិតគ្នាផង។ ចៅពិនគក់ផងច្របាច់ផង តែមិនសូវចូលច្របាច់ទេ ពីព្រោះសាច់លោកម៉ាំងរឹងពេក ដោយមានសាច់ដុំច្រើន ជារឿយៗគេកាច់ជើង កាច់ដៃកាច់ម្រាមព្រះប្រោះៗទាំងអស់គ្នាចូលចិត្តវិធីនេះជាង ម្លោះហើយតែកាលណាកាច់គ្រប់កន្លែងហើយក៏អាចឈប់បានដែរ ក្នុងពេលជាមួយគ្នានោះ កម្មវិធីល្ខោនបាសាក់ ឬនិទានរឿងដោយចាប៊ុដងវែងក្នុងកម្មវិធីវិទ្យុជាតិនៅកំដររងំរហូតដល់ម៉ោង១០យប់ ទើបអស់កម្មវិធីជូនកាលវិទ្យុដាក់ថ្មពិលនៅបើកចោលទល់ភ្លឺក៏មាន ប៉ុន្តែភ្លើងអគ្គិសនីបានត្រូវបិទ តាំងតែពីម៉ោង៩យប់នៅពេលមានទាហ៊ានផ្លុំត្រែ "រ៉ឺត្រែត" មកម្ល៉េះ។

ស្អែកព្រឹកឡើងមិនទាន់ភ្លឺផង ជាពិសេសមិនទាន់ម៉ោង៤ព្រឹកផង លោកម៉ាំងក្រោករួចជាស្រេចដើរតិបតុបពេញផ្ទះ មិនដឹងជាធ្វើអ្វីខ្លះទេ វេលាម៉ោង៥ទើបលោកស្រីប្តើមក្រោក ធ្វើអាហារពេលព្រឹកជូនលោកប្រុសជាទូទៅ ពូរិនរៀបរួចជាស្រេចសម្រាប់លោកស្រីធ្វើអាហារពេលព្រឹកនោះ ព្រឹកនេះមានបបរសជាមួយត្រីងៀតរ៉ស់នឹងសាច់ក្រកជ្រូកពេលខ្លះទៀតក៏មាន "ថូស" ជានំបុ័ងបន្ទះអាំងបៀកនឹងប៊ើពិសារជាមួយត្រណាប់ផ្លែឈើខុសគ្នាច្រើនមុខជាការស្រស់ស្រូបរបៀបបារាំង ។ នៅសាលានាយទាហ៊ានលោក ម៉ាំង តែងទទួលម្ហូបរបៀបបារាំងច្រើនដងក្នុង១អាទិត្យដល់ក្រោយមកធ្វើការជាមួយបារាំងជាមេកើយ ក៏ត្រូវចេះធ្វើម្ហូបបារាំងខ្លះស្គាល់របៀបរបបបារាំងឱ្យបានច្រើនថែមទៀត។ រីឯចៅពិននឹងបងស្រីភ្ញាក់ពីដំណេកនៅម៉ោង៦រៀបចំខ្លួនទៅរៀន ហើយចៅពិនត្រូវទៅវត្ត, តែមុននឹងស្រស់ស្រូបអ្នកទាំងពីរតែងដណ្តើមគ្នាទៅរើសពងមាន់ពងទា នៅឯទ្រុងមាន់ទ្រុងទា យកមកឱ្យម្តាយជានិច្ច ។

ម៉ោង៧ខ្វះ១០ ទាហ៊ានផ្លុំត្រែ "រ៉ាសមប្លឺម៉ង់" រួចគេផ្លុំត្រែ "គោរពទង់ជាតិ Salut au couleur" ម៉ោង៧គត់ ធ្វើចប់ពូសាយក៏មកដល់ផ្ទះល្មមមកទទួលចៅពិន ដែលត្រៀមខ្លួនរួចជាស្រេចដើម្បីចេញដំណើរទៅវត្តថ្មី។ ពូសាយបាននាំចៅពិនទៅបង្ហាញខ្លួននៅមុខលោកកុម៉ង់ដង់ហើយទើបចេញដំណើរទៅ ដើរកាត់ឆ្លងស្ទឹងដូចម្សិលមិញដែរ ហើយមុនឆ្លងទឹកពូសាយ ហៅចៅពិន ឱ្យមកជិះកគាត់ទៀត គួរឱ្យរីករាយណាស់។ ទៅដល់ថ្វាយបង្គំលោកគ្រូនៅម៉ោង៧កន្លះ លោកគ្រូនៅរ៉ូសរ៉ាសចេញបញ្ជាទៅលោកសង្ឃខ្លះទៅលោកតាលោកយាយខ្លះមុននឹងប្រាប់ថា "លោកនឹងទៅបិណ្ឌបាត្រនៅខាងចំបក់ នាព្រឹកនេះ" ប្រគល់កូនសិស្សហើយ ពូសាយក៏ថ្វាយបង្គំត្រឡប់ទៅវិញ រីឯលោកគ្រូក៏ដល់ពេល ចេញដំណើរទៅដែរហើយ ៕

**តទៅលេខក្រោយ**

**Continued from page 15**

# RULING PARTY, OPPOSITION...

party had earned Mr. Hun Sen's vote.

"A 'white eyes' just asked me who I voted for," he said, using a phrase used to describe Westerners.

"It looks stupid if the foreigner asks questions like that," he said, adding it was every citizen's right to keep their choice a secret.

Several hours later, CNRP President KemSokha cast his ballot at a primary school in Phnom Penh's Meanchey district.

Fresh from a two-week campaign tour that crisscrossed the country, Mr. Sokha said he hoped the party would "get more than 60 percent," seeming to repeat past predictions that the CNRP would win that share of the popular vote.

"I know the strength of our support has increased since the last time," he said, before seeming to take aim at the prime minister and other top CPP officials who have warned of violence if the opposition takes power.

"I believe that people don't want a villain" in charge, he said.

The path that led Mr. Sokha to the polling station symbolizes the party president's tangles with the law last year.

The lawmaker represents Kompong Cham province and used to cast his ballot there, but a series of court cases last year sent him into hiding at CNRP headquarters to dodge arrest. Mr. Sokha briefly left the headquarters in October to register to vote and was granted a royal pardon in December for the charge that had led authorities to seek his arrest.

Mr. Sokha and, in a break from past campaign seasons, Mr. Hun Sen, both spoke at peaceful end-of-campaign rallies for their respective parties in Phnom Penh on Friday that mobilized tens of thousands, if not more than 100,000, supporters from each side. Both leaders returned to old themes, with Mr. Sokha urging change and decentralization and the prime minister warning of war if the opposition took power.

That enthusiasm took a more quiet turn at Kolab 1 primary school on Sunday, which hosted five polling sites for Phnom Penh residents of Daun Penh district's SrahChak commune.

Some 80 percent of voters at one of the five polling sites had already cast their ballot by 11 a.m., according to CPP election observer Thach Kimnhunt. Ms. Kimnhunt and other observers from the CNRP, Comfrel and the Cambodian Youth Federation said the election at the station had proceeded smoothly, with voters largely already aware of the procedures.

Health Ministry employee IengSiripong, 45, accompanied by his elderly parents, said that he had observed none of the attempts at coercion that accompanied past votes.

"It's better than before," he said. "People know how to vote."

Voting was also a family affair for 40-year-old PichTekimPhean, whose floral blouse matched the one worn by her mother.

"I was so happy I couldn't sleep last night," she said. And the vote itself had been a breeze, she said. "I didn't have to wait at all."

UchTheary, on the other hand, said it taken her half an hour to cast her ballot.

"I feel excited," the 22-year-old secretary said. "I voted for the one I love."

Mr. Bunthet, the political analyst, predicted the mellow mood would not survive the next year as both parties eyed the crown prize of a 2018 national election victory.

"I think there's going to be a lot of challenges of the vote, a lot of pressure," he said.

(Additional reporting by Hannah Hawkins, KuchNaren, Sek Odom, Chhorn Phearun, Janelle Retka, Ouch Sony and Matt Surrusco)

paviour@cambodiadaily.com, roeun@cambodiadaily.com, obyrne@cambodiadaily.com

## បើកទំព័រថ្មីសម្រាប់ទទួលយោបល់លោកអ្នកអាន

ដើម្បីចូលរួមស្វាគមន៍ឆ្នាំ២០១៧, យើងមានសេចក្តីរីករាយនឹងបើកទំព័រថ្មីម្រាប់ទទួលផ្សាយដោយសេរីនូវគំនិតយោបល់នឹងព័ត៌មានផ្សេងៗដែលលោកអ្នកអានមានបំណងធ្វើការផ្សព្វផ្សាយជាសាធារណៈនៅរៀងរាល់ពេលដែលយើងទទួលបាននូវអត្ថបទថ្មីពីលោកអ្នក។

សូមផ្ញើរអត្ថបទ រូបថត ឬ រូបគំនូរ មក info@khmerpost.us សម្រាប់អ្នកដែលចេះប្រើ "អាំងទែណេត" ឬក៏ផ្ញើរមកអស័យដ្ឋាន Khmerpost U.S.A. Editorial

45, Merrimack Street, #218A

Lowell, Lowell MA 01852_USA

សូមសរសេរដោយដៃក្នុងចន្លោះខាងក្រោមនេះរួចកាត់ផ្ញើរមកយើងខ្ញុំ

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

យើងជឿជាក់ថា គំនិត យោបល់ នឹងព័ត៌មានពីលោកអ្នកនឹងជួយជាប្រយោជន៍ដល់សហគមន៍ញាតិមិត្ត ក្រុមគ្រួសារជាមិនខាន។ សូមកុំភ្លេចដាក់ឈ្មោះ ឬដាក់រូបថត សម្រាប់សំគាល់ម្ចាស់អត្ថបទផង។ **-សូមអរគុណ-**


## កាសែតដែលបំរើសហគមន៍ខ្មែរមានអ្នកអានច្រើនជាងគេបង្អស់នៅឆ្នេរខាងកើតសហរដ្ឋអាមេរិកតាំង១០ឆ្នាំមកហើយ

**KhmerPost USA, LLC**

សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក

អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852

លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092

អ៊ីម៉ែល info@khmerpost.us

អានកាសែតនៅគេហទំព័រ www.khmerpost.us

ផ្សាយពាណិជ្ជកម្ម **Advertising**

អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*

លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)

អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ **Editorials**

និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*

(978) 942 - 1641 | rogerpin@khmerpost.us

ការីនិពន្ធ Staff Writers:

អ្នកនិពន្ធកិត្តិយស **Contributing Writers:**

Richard Howe Jr,

ច្នៃសោភ័ណភាពកាសែត **Design Artist**

Heng Chhunleng

ជំនួយការរដ្ឋបាល Office Coordnator

Sochet Chhen

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

Follow us: Facebook | Twitter @KhmerpostUSA

(អស័យដ្ឋានអ្នកផ្ញើរ)

បិតតែម

Khmerpost U.S.A., Editorial Dep.
45, Merrimack Street, #218A
Lowell, Lowell MA 01852_
USA

បត់ជា២........................................................................................................

**អត្ថបទក្នុងសំបុត្រនេះ:**

**១-** ជាអត្ថបទ ឬ ព័ត៌មាន សុំឱ្យចុះផ្សាយ
**២-** ជាសំនួរ សុំឱ្យឆ្លើយតាមទំព័រកាសែត
**៣-** ជាសំនួរ សុំឱ្យឆ្លើយតប មិនឱ្យផ្សាយទេ
សំបុត្រនេះអាចបត់ជាពីរ បិទការខាង២ បិតតែមមួយ រួចផ្ញើរមកយើងតាមប៉ុស្តិ៍
- សូមគូសនៅ ១-២ ឬ ៣ ដែលត្រូវនឹងសំបុត្រនេះ

Continued from page 01

## GOVERNMENT PANS US AMBASSADOR'S...

comments that were dismissed by one government spokesman as characteristically manipulative and duplicitous.

Speaking on the weekly "Let's Chat" show on the U.S. Embassy Facebook page, Mr. Heidt said the embassy had sent 40 teams across 14 provinces to observe Sunday's vote.

The election, he said, went "very well." But "there was some very hard rhetoric before the election."

"Some of the government ministers said some very strong things. I think that would have been better if that didn't happen," he added.

Defense Minister Tea Banh said he would "smash the teeth" of anyone who dared to protest the election results. Numerous senior officials warned that an opposition victory would spark war, with Prime Minister Hun Sen himself saying that he was willing to "eliminate 100 or 200 people" to prevent that outcome.

With Cambodia canceling annual military drills with the U.S. in January and bristling at perceived criticism from the U.S. Embassy as it cozies closer to China, Mr. Heidt said one of the most challenging parts of his job was selling U.S. cooperation to a "suspicious" Cambodian government.

It was difficult explaining that "some of the things we're trying to do, we're doing for very logical reasons that make sense for both countries," he said.

But Cambodia has every reason to doubt "manipulative" U.S. intentions, according to Council of Ministers spokesman PhaySiphan.

The government appreciated U.S. President Donald Trump's vow not to interfere in other countries' affairs, he said. But the local embassy continued to meddle by issuing statements and sowing anti-government sentiments in the population, according to Mr. Siphan.

"One hand they shake hand with the government, the other they interfere with the internal affairs of the government," he said.

Mr. Siphan added that the "strong things" said by the ministers were just warnings, not threats, made in the name of law and order.

"We don't want anyone [to] cause any trouble during…or after the election," he said.

**តមកទំព័រទី ០២** 
## "ខលី" ឬ "ដោនថោន" ដាន់ រូក...

សេចក្តីសម្រេចនេះ ខ្ញុំជឿជាក់ថា សមាជិកក្រុមប្រឹក្សាម្នាក់ៗនឹងធ្វើការសម្រេចតាមសប្បជញ្ញរបស់គេតាមគំនិតដែលប្រសើរបំផុតរបស់គេ...

**ខ្មែរផុសស.រ.អា:** តើលោកមានសង្ឃឹមថានឹងមាន "ខលី" ច្រើនទេ ?

**ដាន់ រូក:** ខ្ញុំមិនដឹងមែនថា ក្រុមប្រឹក្សានឹងសម្រេចជាបញ្ចប់ថាទៅខាងណាទេ តែខ្ញុំជឿថាគេនឹងធ្វើតាមការស្រាវជ្រាវដ៏វិជ្ជមានរបស់គេថាអ្វីដែលប្រសើរបំផុតសម្រាប់ការសិក្សានៅឡូវែល...

**ខ្មែរផុសស.រ.អា:** ខ្ញុំគិតថា ដោយយោងទៅតាមការបែកយោបល់គ្នាស្រឡះយ៉ាងនេះ បើទោះជាសម្រេចយកទីតាំងវិទ្យាល័យនៅកន្លែងណាមួយក៏ដោយមុខជានឹងមានការទទួលខុសត្រូវខ្ពស់បំផុត ក៏មានមនុស្សពាក់កណ្តាលក្រុងបន្ទោសលោកដែរ មែនទេ?

**ដាន់ រូក:** មែនហើយ វាមុខជានឹងមានអ្នក "សប្បាយចិត្ត" នឹងអ្នកដែល "អន់ចិត្ត", សេចក្តីសម្រេចលើកនេះនឹងចេញពីបេះដូងពិតរបស់សមាជិកក្រុមប្រឹក្សាម្នាក់ៗ, គេមិនអាចគិតពិការបាត់បង់ការគាំទ្រ នៅពេលបោះឆ្នោតខាងមុខបានទេ, ខ្ញុំសម្រេចចិត្តយកអ្វីដែលផ្តល់លទ្ធផលដ៏ល្អបំផុតសម្រាប់ការសិក្សារបស់យុវជនយើង ។

**ខ្មែរផុសស.រ.អា:** ខ្ញុំក៏ជឿដែរថា សេចក្តីសម្រេចរបស់សាលាក្រុងឡូវែល នៅថ្ងៃ១៣នេះនឹងផ្តល់ការចងចាំយូរឆ្នាំដល់ក្រុមគ្រួសារនៃសហគមន៍ឡូវែលនេះ,... សូមអរគុណ ដែលបានផ្តល់បទសម្ភាសន៍នេះដល់ខ្មែរផុស ។

**កំណត់ :** មកទល់ថ្ងៃច័ន្ទនេះលោកស្រីព្រឹទ្ធសមាជិក ដាណាហ៊ូ និងលោកស្រីព្រឹទ្ធសមាជិក សុង ហ្គាស់ គាំទ្រ "ដោនថោន" ចំណែកឯកាសែតខ្មែរផុស កាសែតឡូសាន់ វិទ្យុ WCAP គាំទ្រ "ខលី" ។



ទិដ្ឋភាពសំណង់បច្ចុប្បន្ននៅដោនថោន

MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229
•សេចក្តីអន្តរាយដល់បុគ្គល
•សំណងបុគ្គល
•ពិការភាពដោយសន្តិសុខសង្គម
•បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
•ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
•បណ្តឹងវិវាទទូទៅ
•ច្បាប់ធានារ៉ាប់រង
•ការរំលោភបទព្រហ្មទណ្ឌ
•គ្រោះថ្នាក់ចរាចរណ៍
•គ្រោះថ្នាក់នៅការដ្ឋាន
•បំណុលអចលទ្រព្យ
•បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ
(978) 458-1229
www.marcottelawfirm.com

Continued from page 11

# AS COUNT TICKS UPWARD,...

compared to 487 spots for the opposition-enough to win the election, he claimed.

CNRP President KemSokha, who predicted during the two-week campaign period that the opposition would win 60 percent of the popular vote, said in a speech at the party headquarters in Phnom Penh on Monday that his party won "almost 500 communes" compared to the 40 won between its two composite parties in the 2012 commune elections.

That improvement "proves that the CNRP has received a victory for the next stage," he said.

A coalition of civil society organizations that dubbed themselves the "Situation Room" will present their own results, which are based on independent monitors, at a news conference this morning, the group said.

Nearly 9 out of 10 registered voters cast their ballots on Sunday, according to the updated NEC turnout data-a revision Sam Kuntheamy, head of the Neutral and Impartial Committee for Free and Fair Elections in Cambodia, attributed to civic engagement rather than foul play.

"Actually, I'm happy to see high turnout," Mr. Kuntheamy said.

The close outcome of the popular vote would be helpful for voters insofar as it would encourage major political parties to pay more attention to their needs, said OuVirak, head of the Future Forum think tank.

"My concern for the CPP is that they read the results of this election wrongly," he said.

The party's deep local networks and incumbent advantage gave it a significant edge over the opposition in commune elections, according to Mr. Virak, making the party's boasts of sweeping victory on Monday seem like either political posturing or naivety.

"The fact that they're losing on such a scale should be a wakeup call," he said, predicting the CPP would "play more politics" with refined messaging and increased pressure on the opposition.

But the CNRP had failed to fully capitalize on its "actually amazing" Election Day performance because it set expectations so high, Mr. Virak said. The party would have been better served by framing the elections as a close race, he said.

Sunday's vote "should be seen as a huge victory for the opposition given all the challenges they had to overcome," he said.

Prince Thomico defended Mr. Sokha's forecast, claiming the party raised the stakes for supporters. He described the election as a "win-win" by virtue of the CNRP's pickups and the CPP's sustained majority of commune seats and votes.

"I think it's enough to reassure the people of Cambodia that there will be no war," he said, referring to threats from Mr. Hun Sen and other CPP leaders that an opposition victory would unleash violence.

"Because if everyone wins, there will be no war."

(Additional reporting by Ben Sokhean)




CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវ៉េយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។

យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បៈ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វិកខឺខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY
INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

Red Rose
ភោជនីយដ្ឋាន RESTAURANT
ផ្កាកុលាបក្រហម ម្ចាស់ថ្មី -ម្ហូបឈ្ងុយឆ្ងាញ់

Pailin Plaza
716 Middlesex St. Ste 1
Lowell, MA 01851

អញ្ជើញមកចូលរួមមិនខុសបំណងទេ សូមអរគុណ!

Mon-Sun
8am -8pm


បាយសាច់ជ្រូកពងទាចៀន


គុយទាវសាច់គោរួមទេ


មីកន្ត្រាំង


បបរគ្រឿង

*ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
*សេវាកម្មរហ័សទាន់ចិត្ត និងរូសរាយរាក់ទាក់

(978) 452-5400



# ដំណឹងរកបុគ្គលិកចែកផ្សាយ

ខ្មែរផុសស.រ.អា.ត្រូវការរកបុគ្គលិកសម្រាប់ចែកផ្សាយកាសែតនៅក្នុងតំបន់មានឡូវែល - លីន រីវែរ - ក្រេងស្តុន រ៉ូដអាយឡិន ។ កាសែតចែក២ដងក្នុង១ខែ ។ បេក្ខជនត្រូវមានប័ណ្ណបើកបរ នឹងធ្លាប់ស្គាល់តំបន់ច្បាស់លាស់ ។

សូមទាក់ទងមកទីស្នាក់ការយើង នៅលេខ **978 - 677 7163**

ឬទាក់ទងមក **សូបិន 978-656 8141**

## បានទទួលមួយ ឬទាំងពីរក្នុងចំណោមប័ណ្ណទាំងនេះ?

# ទទួលយកបន្ថែម។




ទទួលយកអត្ថប្រយោជន៍ច្រើនជាងអ្វីដែលអ្នកបច្ចុប្បន្ន កំពុងទទួលបានពី Original Medicare និង MassHealth ជាមួយគម្រោង **UnitedHealthcare® Senior Care Options (HMO SNP)**។ វារួមបញ្ចូលគ្នានូវវេជ្ជបណ្ឌិតរបស់អ្នក មន្ទីរពេទ្យ និងការគ្រប់ដណ្ដប់ឱសថមានវេជ្ជបញ្ជាគ្រប់ទៅក្នុងគម្រោងមួយ គឺសម្រាប់ បុព្វលាភរ៉ាប់រងគម្រោង **$0**។**

### អត្ថប្រយោជន៍បន្ថែមអាចរួមមាន៖

**ឱសថមានវេជ្ជបញ្ជា**
រាប់ពាន់នៃឱសថអាចប្រើបាន។

**ការគ្រប់ដណ្ដប់លើទន្តសាស្ត្រ**
សហចំណាយ **$0** សម្រាប់ការដាក់ធ្មេញ និងក្រាសធ្មេញពាក់។

**ជំនួយលើមធ្យោបាយធ្វើដំណើរ**
សហចំណាយ **$0**សម្រាប់ការជិះទៅជួបវេជ្ជបណ្ឌិតតាមការណាត់។

**កាតាឡុកផលិតផលសុខភាព**
រហូតដល់ទៅ **$160** ក្នុងឥណទានប្រចាំឆ្នាំដើម្បីទិញ ផលិតផលសុខភាពពីកាតាឡុករបស់យើង។

**ទូរស័ព្ទមកថ្ងៃនេះដើម្បីចុះឈ្មោះ ឬទទួលបានចម្លើយទៅនឹងសំណួររបស់អ្នក។**



BOPHA PEOU
Licensed Sales Agent # 2016784

**Contact # (978) 221-9970, TTY 711**
[8 a.m. – 8 p.m. local time, 7 days a week]

**UHCCommunityPlan.com/MA**

UnitedHealthcare
Community Plan

UnitedHealthcare SCO គឺជាគម្រោងថែទាំសុខភាពដែលមានការសម្របសម្រួលមួយ ដែលមានកិច្ចសន្យាជាមួយ Medicare និងជាប់កិច្ចសន្យាជាមួយកម្មវិធី Commonwealth of Massachusetts Medicaid ។ ការចុះឈ្មោះនៅក្នុងគម្រោងគឺផ្អែកទៅលើការបន្តកិច្ចសន្យាជាថ្មីរបស់គម្រោងជាមួយ Medicare ។ គម្រោងនេះគឺជាកម្មវិធីស្ម័គ្រចិត្ត ដែលអាចរកបានសម្រាប់អ្នកដែលមានវ័យចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ MassHealth Standard និង Original Medicare ។ ប្រសិនបើលោកអ្នកមាន MassHealth Standard ប៉ុន្តែលោកអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបាន Original Medicare លោកអ្នកនៅតែមានសិទ្ធិចុះឈ្មោះក្នុងគម្រោង MassHealth Senior Care Option និងទទួលបានអត្ថប្រយោជន៍ MassHealth ទាំងអស់របស់លោកអ្នកតាមរយៈកម្មវិធី SCO របស់យើង។ ព័ត៌មាននេះគឺមិនមែនជាការពិពណ៌នាពេញលេញអំពីអត្ថប្រយោជន៍នោះទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកគម្រោង។ ការកំណត់សហចំណាយ និងការដាក់កំហិតនានាអាចត្រូវអនុវត្ត។ អត្ថប្រយោជន៍ បុព្វលាភរ៉ាប់រង និង/ឬសហចំណាយ/សហធានារ៉ាប់រងអាចផ្លាស់ប្ដូរនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ បុព្វលាភរ៉ាប់រង សហចំណាយ សហធានារ៉ាប់រង និង ថ្លៃបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យ អាចប្រែប្រួលតាមកម្រិតនៃជំនួយបន្ថែមដែលលោកអ្នកទទួលបាន។ សូមទាក់ទងមកគម្រោងសម្រាប់ព័ត៌មានលំអិតបន្ថែមទៀត។ អ្នកចុះឈ្មោះមិនតម្រូវឲ្យបង់ប្រាក់ពីហៅប៉ៅឡើយ។

H2226_150915_093829 Accepted
UHCSCO_150915_093829

CST10056_ H2226-001

# សារព័ត៌មាន ខ្មែរផុស ស.រ.អា KhmerPost USA

*Cambodian American Biweekly Newspaper*

## ផ្សព្វផ្សាយទៅដល់អ្នកអានក្នុងសហគមន៍ខ្មែរច្រើនជាងគេបង្អស់នៅសហរដ្ឋអាមេរិក

កាសែតខ្មែរផុស ស.រ.អា គឺជាកាសែតភាសារខ្មែរ- អង់គ្លេសពណ៌ធម្មជាតិ មានចំនួន៣២ទំព័រដែលបោះពុម្ពផ្សាយជារៀងរាល់ពីរសប្តាហ៍ម្តងចំនួន៥,០០០ច្បាប់ និងធ្វើការបែងចែកដោយមិនគិតថ្លៃទៅកាន់៦០កន្លែងក្នុងតំបន់ឡូវែល។ រៀបចំពេលវេលាផ្សព្វផ្សាយពាណិជ្ជកម្មសម្រាប់ឆ្នាំ២០១៧ របស់លោកអ្នកជាមួយយើងខ្ញុំថ្ងៃនេះ!

Connecting 50,000 Khmer-speaking readers per month.
Free Newspaper copies are available in these cities:

Massachusetts:

- Lowell
- Lynn/Revere

Rhode Island:

- Providence
- Cranston

<u>កាលបរិច្ឆេទនៃការបោះពុម្ពផ្សាយ :</u>

- ថ្ងៃទី ១២ និង ២៦ ខែមិថុនា
- ថ្ងៃទី ១០ និង២៤ ខែកក្កដា
- ថ្ងៃទី ០៧ និង ២១ ខែសីហា
- ថ្ងៃទី ១១ និង ២៥ ខែតុលា
- ថ្ងៃទី ០៩ និង ២៣ ខែកញ្ញា
- ថ្ងៃទី ០៦ និង២០ ខែវិច្ឆិការ
- ថ្ងៃទី ០៤ និង ១៨ ខែធ្នូ

**<u>2017 Print Dates</u>**

- June 12, 26
- July 10, 24
- August 07, 21
- September 11, 25
- October 09, 23
- November 06, 20
- December 04, 18



Soben Pin, Co-founder/Managing Partner;
Sochet Chhen, Office Coordinator

* រាល់ព័ត៌មាននៃការផ្សព្វផ្សាយទាំងអស់ ត្រូវផ្ញើមកកាន់យើងខ្ញុំឲ្យបាន ៣ ថ្ងៃមុនការបោះផ្សាយ។

**ទំនាក់ទំនងមក ពិន សុបិន សម្រាប់ឱកាសនៃការផ្សព្វផ្សាយពាណិជ្ជកម្មរបស់លោកអ្នក**

**Contact Soben Pin For Advertising Opportunities**
**Email: sobenpin@khmerpost.us**

**978-677-7163**

ម៉ោងបំរើការងារ: ថ្ងៃច័ន្ទ - សុក្រ ចាប់ពី 9:00 ព្រឹក ដល់ម៉ោង ៤:00 ល្ងាច
អសយដ្ឋានការិយាល័យ**កាសែតខ្មែរផុសស.រ.អា**

Office: KhmerPost USA, LLC. 45 Merrimack St. Suite 218A. Lowell, MA 01852
Hours: Monday – Friday. 9AM – 4PM
**VISIT KHMERPOST.US**




**Merrimack Valley Food Bank is a Proud Sponsor of the USDA Summer Food Service Program 2017!!**

**Serving Lunches/Snacks to Children 18 and younger July thru August at a location below: (L) = Lunch (S) = Snack**

| | | |
|---|---|---|
| Caleb Group 77 Chestnut St. | (L) 11:00 - 12:00 (S) 2:00-2:30 | July 10th - Aug. 17th |
| Christ Jubilee 101 Smith St. | (L) 12:00-12:45 | July 10th - Aug. 18th |
| Eagle Park 95 W. 6th St. | (L) 11:15-11:45 | July 10th - Aug. 18th |
| LCHC - Teen Block 161 Jackson St. | (L) 12:00 - 1:00 (S) 3:45-4:30 | July 10th - Aug. 17th |
| LCHC - Teen Block 33 Kearney Sq. | (S) 3:00 – 3:30 | July 10th - Aug. 16th |
| Lowell Housing Authority 580 Chelmsford St. | (L) 12:00 -12:45 | July 11th - Aug. 18th |
| Lowell Housing Authority 21 Salem St. | (L) 11:45-12:30 | July 11th - Aug. 18th |
| McPherson Pool 1000 Bridge St. | (L) 12:15 -1:00 | July 10th - Aug. 18th |
| North Canal Summer Program 517 Moody St. | (S) 9:15-9:45 (L) 12:00 -12:45 | July 11th - Aug. 18th |
| O'Donnell Splash Pad 1170 Gorham St. | (L) 1:30 -2:00 | July 10th – Aug. 18th |
| Lord Memorial Swimming Pool 81 Cross St. | (L) 12:15-1:00 | July 06th – Aug. 18th |
| YWCA 41 Rock St. | (L) 12:00-12:30 (S) 3:00 - 4:00 | July 10th – Aug. 18th |

USDA is an equal Opportunity Provider and Employer